# អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងបណ្តាញអំពើឧក្រិដ្ឋកម្មឆ្លងដែន

## មាត្រា ១

### សេចក្តីថ្លែងការណ៍អំពីគោលបំណង:

អនុសញ្ញានេះ មានគោលបំណងលើកកំពស់កិច្ចសហប្រតិបត្តិការគ្នា ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងបណ្តាញអំពើឧក្រិដ្ឋកម្មឆ្លងដែនឱ្យកាន់តែមានប្រសិទ្ធិភាពឡើងថែមទៀត ។

## មាត្រា ២

### ការប្រើប្រាស់ពាក្យ:

សំរាប់គោលបំណងរបស់អនុសញ្ញានេះ:

(ក) *"ក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង* មានន័យថា: ជាក្រុមមួយដែលមានរចនាសម្ព័ន្ធមនុស្សចំនួន ៣នាក់ ឬច្រើននាក់ ដែលមានអត្ថិភាពនៅក្នុងរយ:ពេលមួយ និងធ្វើសកម្មភាពរួមគ្នាក្នុងគោលដៅដើម្បីប្រព្រឹត្តអំពើ ឧក្រិដ្ឋកម្មធ្ងន់ធ្ងរមួយ ឬ ច្រើន ឬបទល្មើសមួយ ឬ ច្រើន ដូចដែលត្រូវបានកំណត់ដោយតាមអនុសញ្ញានេះ ដើម្បីទទួលបាននូវផលប្រយោជន៍មួយ ដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី ជាហិរញ្ញវត្ថុ ឬជាសំភារ: ផ្សេងៗទៀត ។

(ខ) " *បទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរ* " មានន័យថា: អាកប្បកិរិយាដែលបង្កើតបានជាបទល្មើសមួយ ដែលអាចត្រូវបានផ្តន្ទាទោស ដោយការដកហូតនូវសេរីភាពជាអតិបរិមា យ៉ាងហោចណាស់រយ:ពេល ៤ ឆ្នាំ ឬ ដោយទណ្ឌកម្មមួយធ្ងន់ធ្ងរជាង ។

(គ) *"ក្រុមដែលមានរចនាសម្ព័ន្ធ* " មានន័យថា: ជាក្រុមមួយ ដែលមិនត្រូវបានបង្កើតឡើងដោយចៃដន្យ ដើម្បីប្រព្រឹត្តបទល្មើសមួយភ្លាមៗ និងមិនចាំបាច់មានការចាត់តាំងអំពី តួនាទីជាផ្លូវការសំរាប់សមាជិក និរន្តភាពនៃសមាជិកភាព ឬរចនាសម្ព័ន្ធមួយដែលត្រូវការបង្កើតរបស់វានោះឡើយ ។

(ឃ) " *ទ្រព្យសម្បត្តិ* " មានន័យថា: ជាទ្រព្យគ្រប់បែបយ៉ាង ដែលអាចមានរូបរាង ឬគ្មានរូបរាង ជាចលនវត្ថុ ឬអចលនវត្ថុ អាចបះពាល់ ឬមិនអាចបះពាល់បាន និងជាឯកសារផ្លូវច្បាប់ ឬជាលិខិតុបករណ៍ ដែលជាភស្តុតាងបញ្ជាក់អំពីសិទ្ធកម្មសិទ្ធិ ឬអំពីផលប្រយោជន៍លើទ្រព្យបែបនេះ ។

(ង) " *ទ្រព្យនៃឧក្រិដ្ឋកម្ម* " មានន័យថា: ជាទ្រព្យណាមួយ ដែលបានមក ឬទទួលបានដោយផ្ទាល់ ឬដោយប្រយោល តាមរយ:ការប្រព្រឹត្តិបទល្មើសមួយ ។

(ច) " *ការបង្កាំង* " ឬ " *ការរឹបអូស* " គឺមានន័យថា: ជាការហាមឃាត់ជាបណ្តោះអាសន្ន ចំពោះការផ្ទេរ ការផ្លាស់ប្តូរ ការចាត់ចែង ឬការធ្វើបំលាស់ទីទ្រព្យសម្បត្តិ ឬការទទួលថែរក្សា ឬការត្រួតពិនិត្យទ្រព្យសម្បត្តិជាបណ្តោះអាសន្ន ដោយផ្អែកលើបញ្ជារមួយដែលចេញដោយតុលាការមួយ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀត។

(ឆ) " *ការដកហូត* " ដែលរាប់បញ្ចូលទាំងការប្រាកចាកសិទ្ធិដែលអាចយកមកអនុវត្តនីបាន គឺមានន័យថា: ជាការផ្តាច់ជាអចិន្ត្រៃយ៍នូវសិទ្ធលើទ្រព្យសម្បត្តិដោយមានដីកាពីតុលាការមួយឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀត។

(ជ) " *បទល្មើសចំបង* " មានន័យថា : ជាបទល្មើសណាមួយ ដែលបង្កើតឱ្យមានផល ដែលអាចក្លាយទៅជាកម្មវត្ថុនៃបទល្មើសមួយទៀត ដូចដែលត្រូវបានកំណត់នៅក្នុងមា ត្រា ៦ នៃអនុសញ្ញានេះ។

(ឈ) " *ការប្រគល់ដែលជាប់ការត្រួតពិនិត្យ* " មានន័យថា: ជាបច្ចេកទេសនៃការអនុញ្ញាតឱ្យ ទំនិញខុសច្បាប់ ឬជាប់មន្ទិលសង្ស័យបានចេញផុត ឆ្លងកាត់ ឬចូលទៅក្នុង ទឹកដីនៃរដ្ឋមួយ ឬរដ្ឋជាច្រើន ដោយបាន ដឹង និងស្ថិតនៅក្រោមការពិនិត្យរបស់អាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដោយបានដឹងអំពីការស៊ើបអង្កេតលើបទល្មើសមួយ និងការបង្ហាញអត្តសញ្ញាណបុគ្គល ដែលបានជាប់ពាក់ព័ន្ធនៅក្នុងការប្រព្រឹត្តិបទល្មើសនោះ។

(ញ) " *អង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់* " មានន័យថា: ជាអង្គការណាមួយ ដែលត្រូវបាន បង្កើតឡើងដោយបណ្តារដ្ឋអធិបតេយ្យនៅក្នុងតំបន់ណាមួយ ដែលបណ្តារដ្ឋជាសមាជិករបស់ខ្លួន បានផ្ទេរសមត្ថកិច្ច ដែលទាក់ទងនឹងបញ្ហាដែលកំណត់ដោយអនុសញ្ញានេះ និងដែលបានទទួលការអណត្តិដោយ ត្រឹមត្រូវ ស្របតាមនីតិវិធីក្នុងប្រទេសរបស់ខ្លួន ដើម្បីចុះហត្ថលេខា ផ្តល់សច្ចាប័ន ព្រមទទួលយក អនុម័តទទួលយក ឬ ចូលជាសមាជិក។ ការនិយាយសំដៅទៅលើ "**រដ្ឋភាគីទាំងឡាយ** " នៅក្នុងអនុសញ្ញានេះអាចអនុវត្តចំពោះ អង្គការបែបនេះ តែនៅក្នុងវង្វង់ដែនកំណត់នៃសមត្ថកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ។

## មាត្រា ៣

## វិសាលភាពនៃការអនុវត្តន៍:

១- លើកលែងតែបទល្មើសដែលមិនបានបញ្ជាក់នៅក្នុងនេះ អនុសញ្ញានេះអនុវត្តដើម្បីទប់ស្កាត់ ស៊ើបអង្កេត និងចោទប្រកាន់ចំពោះ:

(ក) បទល្មើសទាំងឡាយ ដែលបានកំណត់ឡើងដូចមាននៅក្នុងមាត្រា ៥ មាត្រា ៦ មាត្រា ៨ និងមាត្រា ២៣ នៃអនុសញ្ញានេះ និង

(ខ) បទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរដូចបានកំណត់នៅក្នុងមាត្រា ២ នៃអនុសញ្ញានេះ ដែលបទល្មើសនោះមានចរិតលក្ខណៈឆ្លងដែន និងមានការពាក់ព័ន្ធជាមួយនឹងក្រុមបណ្ដាញឧក្រិដ្ឋជនមួយក្រុម ។

២- សំរាប់គោលដៅរបស់កថាខណ្ឌទី ១ នៃមាត្រានេះ បទល្មើសមួយ ត្រូវបានចាត់ទុកថាមានចរិតលក្ខណៈឆ្លងដែន ប្រសិនបើវាៈ

(ក) ត្រូវបានប្រព្រឹត្តនៅក្នុងរដ្ឋច្រើនជាងមួយ

(ខ) ត្រូវបានប្រព្រឹត្តនៅក្នុងរដ្ឋមួយ ប៉ុន្តែផ្នែកសំខាន់នៃការរៀបចំ ការធ្វើផែនការ ការដឹកនាំ ឬការត្រួតពិនិត្យរបស់វាមួយ បានចាត់ចែងឡើងនៅក្នុងរដ្ឋមួយផ្សេងទៀត

(គ) ត្រូវបានប្រព្រឹត្តនៅក្នុងរដ្ឋមួយ ប៉ុន្តែវាមានការពាក់ព័ន្ធជាមួយនឹងក្រុមបណ្ដាញ ឧក្រិដ្ឋជនមួយក្រុម ដែលបានធ្វើសកម្មភាពឧក្រិដ្ឋនៅក្នុងរដ្ឋច្រើនជាងមួយ ឬ

(ឃ) ត្រូវបានប្រព្រឹត្តនៅក្នុងរដ្ឋមួយ ប៉ុន្តែវាមានផលប៉ះពាល់មួយផ្នែកធំនៅក្នុងរដ្ឋមួយ ផ្សេងទៀត ។

## មាត្រា ៤

### ការការពារអធិបតេយ្យភាពៈ

១-រដ្ឋភាគីទាំងឡាយ អនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្នុងអនុសញ្ញានេះ នៅក្នុងលក្ខណៈមួយស្របតាមគោលការណ៍សមភាពនៃអធិបតេយ្យភាព និងបូរណភាពដែនដីរបស់បណ្ដារដ្ឋនានា និងការមិនចូលជ្រៀតជ្រែកទៅក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋផ្សេងៗទៀត ។

២-គ្មានបទបញ្ញត្តិណាមួយនៃអនុសញ្ញានេះដែលអនុញ្ញាតឱ្យរដ្ឋជាភាគីមួយ បំពេញលើទឹកដីនៃរដ្ឋមួយផ្សេងទៀតទេ នូវសមត្ថកិច្ច និងមុខងារ ដែលត្រូវបានប្រគល់ផ្ដាច់មុខ ដល់អាជ្ញាធរផ្សេងៗនៃរដ្ឋនោះដោយច្បាប់ក្នុងស្រុករបស់ខ្លួនឡើយ ។

## មាត្រា ៥

## ការកំណត់បទល្មើសព្រហ្មទណ្ឌចំពោះការចូលរួមក្នុងក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង :

១-រដ្ឋភាគីនិមួយៗ ត្រូវតែអនុម័តវិធានការនីតិបញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលចាំបាច់ដើម្បីកំណត់ឱ្យជាបទល្មើសព្រហ្មទណ្ឌ នៅពេលដែលវាត្រូវបានប្រព្រឹត្ត ដោយចេតនា ចំពោះ :

(ក) អំពើណាមួយ ឬអំពើទាំងពីរខាងក្រោមនេះ ជាបទល្មើសព្រហ្មទណ្ឌ ដោយមិនគិតអំពីការប៉ុនប៉ង ឬការសំរេចសកម្មភាពល្មើស :

(១) ព្រមព្រៀងជាមួយនឹងបុគ្គលម្នាក់ ឬបុគ្គលច្រើននាក់ផ្សេងទៀត ដើម្បីប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរមួយក្នុងគោលបំណងមួយ ដែលមានការទាក់ទងដោយផ្ទាល់ ឬដោយប្រយោលដើម្បីទទួលបាន ផលប្រយោជន៍ខាងហិរញ្ញវត្ថុ ឬផលប្រយោជន៍ខាងសំភារៈផ្សេងៗទៀត និង (បើតម្រូវដោយច្បាប់ក្នុងស្រុក) មានការពាក់ព័ន្ធជាមួយនឹងអំពើមួយ ដែលត្រូវបានប្រព្រឹត្តដោយអ្នកចូលរួមម្នាក់ក្នុងចំណោមអ្នកចូលរួមទាំងនោះដោយធ្វើទៅតាមការព្រមព្រៀងគ្នានោះ ឬមានការពាក់ព័ន្ធជាមួយនឹងក្រុមបណ្តាញឧក្រិដ្ឋជនមួយក្រុម

(២) ការចូលរួមដោយបុគ្គលម្នាក់ ដែលបានដឹងអំពីគោលដៅ និងសកម្មភាពឧក្រិដ្ឋជាទូទៅរបស់ក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំងមួយ ឬគោលបំណងរបស់ក្រុមនោះដើម្បីប្រព្រឹត្តបទល្មើសដែលមាន បញ្ហានោះ ដែលបានដើរតួនាទីយ៉ាងសកម្មនៅក្នុង:

ក- សកម្មភាពឧក្រិដ្ឋរបស់ក្រុមបណ្តាញឧក្រិដ្ឋជននោះ

ខ- សកម្មភាពផ្សេងៗទៀតរបស់ក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំងនោះ ដោយ ដឹងថាការចូលរួមរបស់ខ្លួន នឹងរួមចំណែកឱ្យមានការសំរេចគោលដៅនៃអំពើឧក្រិដ្ឋកម្មដែលបានរៀបរាប់មកខាងលើនេះ ។

(ខ) ការរៀបចំ ការដឹកនាំ ការជួយសំរួល ការលើកទឹកចិត្ត ការសំរបសំរួល ឬការពិគ្រោះយោបល់ដល់ការប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌ ដែលពាក់ព័ន្ធជាមួយនឹង ក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំងមួយ ។

២-ការបានដឹង គោលបំណង គោលដៅ មូលហេតុ ឬការព្រមព្រៀងគ្នា ដែលបាននិយាយសំដៅនៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ អាចត្រូវបានសន្និដ្ឋានថាមានតាមរយៈស្ថានអង្គហេតុមិនបំផ្លើស ។

៣- រដ្ឋភាគីទាំងឡាយ ដែលច្បាប់ក្នុងស្រុករបស់ខ្លួន តំរូវថា ការកំណត់ជាបទល្មើស ស្របតាមកថាខណ្ឌទី ១ ចំនុច (ក) និងចំនុច (១) នៃមាត្រានេះ ចំពោះការពាក់ព័ន្ធក្នុងក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង ត្រូវតែធានាថាច្បាប់ក្នុងស្រុករបស់ខ្លួននោះ មានចែងអំពីបទល្មើស ព្រហ្មទណ្ឌធ្ងន់ធ្ងរទាំងឡាយ ដែលពាក់ព័ន្ធជាមួយនឹងក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង ។ រដ្ឋភាគីនានាទាំងនេះ ក៏ដូច ជារដ្ឋភាគីទាំងឡាយ ដែលច្បាប់ក្នុងស្រុក របស់ខ្លួន តំរូវថាការកំណត់បទល្មើស ដូចមានចែងក្នុងកថាខណ្ឌទី ១ ចំនុច (ក) និងចំនុច (១) នៃមាត្រានេះ ចំពោះអំពើចូលរួមដោយធ្វើទៅតាមការព្រមព្រៀងគ្នានោះ ត្រូវតែជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ នៅក្នុងពេលចុះហត្ថលេខា ឬពេលតំកល់លិខិតុបករណ៍នៃ ការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័តទទួលយក ឬនៃការចូលជាសមាជិក។

## មាត្រា ៦

**ការកំណត់បទល្មើសព្រហ្មទណ្ឌចំពោះការលាងផលនៃឧក្រិដ្ឋកម្ម:**

១- រដ្ឋភាគីនិមួយៗ ត្រូវតែអនុម័តវិធានការនីតិបញ្ញត្តិ និងវិធានការចាំបាច់ផ្សេងៗទៀត

រដ្ឋភាគីនិមួយៗ ត្រូវតែអនុម័ត ស្របតាមគោលការណ៍ជាមូលដ្ឋាននៃច្បាប់ក្នុងស្រុករបស់ខ្លួន នូវវិធានការ នីតិបញ្ញត្តិ និងវិធានការផ្សេងៗទៀត ដែលចាំបាច់ ដើម្បីកំណត់ឱ្យជាបទល្មើសព្រហ្មទណ្ឌ នៅពេលដែលវាត្រូវបានប្រព្រឹត្ត ដោយចេតនា ចំពោះ :

(ក) (១) ការផ្លាស់ប្តូរ ឬការផ្ទេរទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិបែបនេះគឺជាផលនៃ អំពើឧក្រិដ្ឋកម្ម ក្នុងគោលបំណង លាក់ ឬបិទបាំងនូវប្រភពដើមនៃទ្រព្យសម្បត្តិខុសច្បាប់នោះ ឬជួយបុគ្គលណាម្នាក់ ដែលមានការពាក់ព័ន្ធនៅក្នុងការ ប្រព្រឹត្តិបទល្មើសចំបងនោះ ដើម្បីគេចចេញពីការទទួលខុសត្រូវខាងផ្លូវច្បាប់ចំពោះសកម្មភាពរបស់ បុគ្គលនោះ

(២) ការលាក់ ឬការបិទបាំងនូវចរិតលក្ខណៈ ប្រភព ទីតាំង ការចាត់ចែង ការធ្វើចរាចរ ឬកម្មសិទ្ធិ ឬសិទ្ធិ ពិតប្រាកដ នៃទ្រព្យសម្បត្តិ ដោយបានដឹងថាទ្រព្យសម្បត្តិបែបនេះ គឺជាផលនៃឧក្រិដ្ឋកម្ម

(ខ) និង ដោយលើកលែងតែជាកម្មវត្ថុនៃទស្សនៈជាមូលដ្ឋាននៃប្រព័ន្ធច្បាប់របស់ខ្លួន :

(១) ការទទួលយក ការកាន់កាប់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិ ដោយបានដឹង នៅពេលទទួលថា ទ្រព្យសម្បត្តិបែបនេះ គឺជាផលឧក្រិដ្ឋកម្ម

(២) ការចូលរួមក្នុង ការសេពគប់ជាមួយ ឬការសមគំនិតគ្នាដើម្បីប្រព្រឹត្ត ឬការប៉ុនប៉ងដើម្បីប្រព្រឹត្ត និង ការផ្តល់ជំនួយ ការជំរុញឱ្យប្រព្រឹត្ត ការសំរបសំរួល និងការពិគ្រោះយោបល់ដល់ការប្រព្រឹត្តិបទល្មើស ណាមួយក្នុងចំណោមបទល្មើសទាំងឡាយ ដែលបានកំណត់ឡើងស្របតាមមាត្រានេះ ។

២-ក្នុងគោលបំណងអនុវត្តន៏ ឬការប្រើប្រាស់កថាខណ្ឌទី ១ នៃមាត្រានេះ:

(ក) រដ្ឋភាគីនិមួយៗ ត្រូវតែខំប្រឹងប្រែងអនុវត្តន៏កថាខណ្ឌទី ១ នៃមាត្រានេះឱ្យបានទូលំទូលាយ បំផុត សំរាប់បទល្មើសចំបងទាំងនោះ

(ខ) រដ្ឋភាគីនិមួយៗ ត្រូវតែរាប់បញ្ចូលថាជាបទល្មើសចំបង ចំពោះបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរទាំងឡាយណាដែលត្រូវបាន កំណត់នៅក្នុងមាត្រា ២ នៃអនុសញ្ញានេះ និងបទល្មើសទាំងឡាយ ដែលបានបង្កើតឡើងស្របតាមមាត្រា ៥ មាត្រា ៨ និងមាត្រា ២៣ នៃអនុសញ្ញានេះ ។ នៅក្នុងករណីដែលរដ្ឋភាគីទាំងឡាយណា ដែលច្បាប់របស់ ខ្លួន បានប្រកាសឱ្យដឹងនូវបញ្ជីនៃបទល្មើសចំបងជាក់លាក់ រដ្ឋភាគីទាំងនោះ ត្រូវតែរាប់បញ្ចូលក្នុងកំរិតជាអប្បបរិមា នៅក្នុងបញ្ជីនោះតាមលំដាប់អាយយល់នូវរាល់បទល្មើសទាំងឡាយដែលមានការទាក់ទងជាមួយនឹង ក្រុមឧក្រិដ្ឋជនដែលមានអង្គការចាត់តាំង

(គ) ក្នុងគោលបំណងរបស់កថាខណ្ឌរង (ខ) បទល្មើសចំបងទាំងឡាយ រាប់បញ្ចូល បទល្មើសដែលត្រូវបានប្រព្រឹត្តទាំងនៅក្នុង និងនៅក្រៅដែនសមត្ថកិច្ចរបស់រដ្ឋភាគីដែលមានបញ្ហានោះ ។ ទោះជាយ៉ាងណាក៏ដោយ បទល្មើសទាំងឡាយ ដែលត្រូវបានប្រព្រឹត្តនៅក្រៅដែនសមត្ថកិច្ចរបស់រដ្ឋភាគីមួយ ត្រូវចាត់ទុកថាជាបទល្មើសចំបងបាន ដរាបណាតែអំពើប្រព្រឹត្តិដែលពាក់ព័ន្ធនោះ គឺជាបទល្មើសព្រហ្មទណ្ឌមួយនៅក្រោមច្បាប់ក្នុងស្រុករបស់រដ្ឋដែលបទល្មើសនេះត្រូវបានប្រព្រឹត្ត ហើយនឹងអាចជាបទល្មើសព្រហ្មទណ្ឌមួយនៅក្រោមច្បាប់ក្នុងស្រុករបស់រដ្ឋភាគី ដែលកំពុងអនុវត្តន៏ ឬកំពុងប្រើប្រាស់មាត្រានេះ ប្រសិនបើបទល្មើសនោះ ត្រូវបានប្រព្រឹត្តនៅទីនោះ ។

(ឃ) រដ្ឋភាគីនិមួយៗ ត្រូវតែផ្តល់អត្ថបទចំលងនៃច្បាប់នានារបស់ខ្លួន ដែលផ្តល់ការចូលជាធរមានដល់មាត្រា នេះ និងអត្ថបទចំលងនៃសេចក្តីកែប្រែជាបន្តបន្ទាប់ណាមួយនៃច្បាប់បែបនេះ ព្រមទាំងសេចក្តីពិពិណនាណាមួយនៃច្បាប់នោះ ឬសេចក្តីកែប្រែសេចក្តីពិពណ៌នានេះនាពេលខាងមុខ ជូន ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ

(ង) ប្រសិនបើតំរូវឱ្យមាន ដោយគោលការណ៍ជាមូលដ្ឋាននៃច្បាប់ក្នុងស្រុករបស់រដ្ឋភាគីមួយ គេអាចចែងថាបទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ មិនត្រូវយកមកអនុវត្តចំពោះ បុគ្គល ដែលបានប្រព្រឹត្តបទល្មើសចំបងនេះទេ

(ច) ការបានដឹង បំណង ឬមូលហេតុ ដែលតំរូវឱ្យមានដើម្បីធ្វើជាផ្នែកមួយនៃបទល្មើសមួយ ដែលមានចែងនៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ អាចត្រូវបានសន្និដ្ឋានថាមានតាមរយៈស្ថានអង្គហេតុមិនបំភ្លើស។

## មាត្រា ៧

### វិធានការដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើលាងលុយក្រខ្វក់:

១- រដ្ឋភាគីនិមួយៗ:

(ក) ត្រូវតែចាប់ផ្តើមអនុវត្ត របបត្រួតពិនិត្យ ដែលកំណត់ដោយច្បាប់ក្នុងស្រុកដ៏ពេញលេញមួយ សំរាប់ស្ថាប័នហិរញ្ញវត្ថុដែលជាធនាគារ និងដែលមិនមែនជាធនាគារ និងតាមការសមស្រប អង្គការផ្សេងៗ ទៀត ដែលមានលក្ខណៈងាយស្រួល ជាពិសេស សំរាប់អំពើលាងលុយក្រខ្វក់ នៅក្នុងវង្វង់ដែនសមត្ថកិច្ច របស់ខ្លួន ដើម្បីរារាំង និងរកឱ្យឃើញនូវអំពើលាងលុយក្រខ្វក់គ្រប់ប្រភេទ ដែលរបបនោះ ត្រូវ មានការបញ្ជាក់អំពីតំរូវការសំរាប់ ការបង្ហាញអត្តសញ្ញាណអតិថិជន ការរក្សាទុកឯកសារ និងការធ្វើសេច ក្តីរាយការណ៍អំពីប្រតិបត្តិការណ៍ដែលមានភាពមន្ទិលសង្ស័យ ។

(ខ) ត្រូវតែធានា ដោយគ្មានការបះពាល់ដល់មាត្រា ១៨ និងមាត្រា ២៧ នៃអនុសញ្ញានេះ ថាការអនុវត្តនីផ្នែករដ្ឋបាល ផ្នែកនីតិបញ្ញត្តិ និងច្បាប់ ហើយនឹងអាជ្ញាធរផ្សេងៗទៀត ដែលទទួលបន្ទុកប្រយុទ្ធប្រឆាំងនឹងអំពើលាងលុយក្រខ្វក់ (រាប់ទាំងអាជ្ញាធរតុលាការតាមភាពសមស្របនៅក្រោមច្បាប់ក្នុងស្រុក) មានសមត្ថកិច្ចដើម្បីធ្វើសហប្រតិបត្តិការ និងផ្លាស់ប្តូរពតិមាននៅថ្នាក់ជាតិ និងថ្នាក់ អន្តរជាតិនៅក្នុងវង្វង់លក្ខខណ្ឌទាំងឡាយ ដែលបានចែងដោយច្បាប់ក្នុងស្រុករបស់ខ្លួន ហើយនឹងត្រូវពិចារណាអំពីការបង្កើតឱ្យមាននូវអង្គភាពពណ៌មានហិរញ្ញវត្ថុមួយ ដើម្បីធ្វើជាមជ្ឈមណ្ឌលថ្នាក់ ជាតិមួយ ដើម្បីប្រមូល វិភាគ និងផ្សព្វផ្សាយពតិមាន ដែលមានការពាក់ព័ន្ធជាមួយនឹងអំពើលាងលុយ ក្រខ្វក់ធំៗ ។

២- រដ្ឋភាគីទាំងឡាយ ត្រូវតែពិចារណាអំពីការអនុវត្តនីវិធានការទាំងឡាយ ដែលអាចធ្វើទៅបាន ដើម្បីរកឱ្យឃើញ និងត្រួតពិនិត្យចលនាលុយ ហើយនឹងឧបករណ៍ទូទាត់សមស្របផ្សេងៗទៀតដែលឆ្លងកាត់ព្រំដែនរបស់ខ្លួន ដែលជាកម្មវត្ថុនៃការការពារ ដើម្បីធានាឱ្យមានការប្រើប្រាស់ពតិមានដ៏សមស្រប និងដោយគ្មានការបង្អាក់នូវចរាចរនៃមូលធនស្របច្បាប់ក្នុងផ្លូវណាមួយឡើយ ។ វិធានការបែបនេះ អាចរាប់បញ្ចូល នូវតំរូវការមួយ ដែល បុគ្គលទាំងឡាយ និងស្ថាប័នជំនួញទាំងឡាយ ត្រូវធ្វើសេចក្តីរាយការណ៍អំពីការ ផ្ទេរឆ្លងកាត់ព្រំដែននូវប្រាក់ និងឧបករណ៍ទូទាត់សមស្របផ្សេងៗទៀត ដែលមានចំនួនច្រើន ។

៣- នៅក្នុងការបង្កើតឡើងនូវរបបត្រួតពិនិត្យ ដែលកំណត់ដោយច្បាប់ក្នុងស្រុកមួយនៅក្រោមអាណត្តិនៃមាត្រានេះ និងដោយគ្មានការប៉ះពាល់ដល់មាត្រាណាមួយផ្សេងទៀតនៃអនុសញ្ញានេះ រដ្ឋភាគីទាំងឡាយ ត្រូវបានអំពាវនាវឱ្យប្រើប្រាស់ គំនិតផ្តួចផ្តើមដែលមានការពាក់ព័ន្ធ ទាំងឡាយរបស់អង្គការតំបន់ អង្គការអន្តរតំបន់ និងអង្គការពហុភាគី ដើម្បីធ្វើជាសេចក្តីណែនាំមួយសំរាប់ប្រយុទ្ធប្រឆាំងនឹងអំពើលាងលុយកខ្វក់នេះ ។

៤- រដ្ឋភាគីទាំងឡាយ ត្រូវតែខិតខំប្រឹងប្រែងដើម្បីបង្កើត និងលើកកំពស់កិច្ចសហប្រតិបត្តិការក្នុងពិភពលោក ក្នុងតំបន់ ក្នុងអនុតំបន់ និងកិច្ចសហប្រតិបត្តិការទ្វេភាគីនៅក្នុងចំណោមស្ថាប័នតុលាការ ស្ថាប័នអនុវត្តន៍ច្បាប់ និងអាជ្ញាធរត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុផ្សេងៗទៀត ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើលាងលុយកខ្វក់នេះ ។

## មាត្រា ៨

## ការកំណត់បទល្មើសព្រហ្មទណ្ឌចំពោះអំពើពុករលួយ:

១- រដ្ឋភាគីនិមួយៗ ត្រូវតែអនុម័តវិធានការផ្នែកនីតិបញ្ញត្តិបែបនេះ និងវិធានការផ្សេងៗទៀត ដែលអាចមានការចាំបាច់ ដើម្បីកំណត់ឱ្យជាបទល្មើសព្រហ្មទណ្ឌ នៅពេលដែលវាត្រូវបានប្រព្រឹត្ត ដោយចេតនាចំពោះ :

(ក) ការសន្យា ការស្នើរ ឬការប្រគល់ដល់មន្ត្រីសាធារណៈម្នាក់ ដោយផ្ទាល់ ឬដោយប្រយោលនូវអត្ថប្រយោជន៍ដោយខុសច្បាប់មួយ ដល់មន្ត្រីនោះ ឬបុគ្គលម្នាក់ ឬអង្គភាពមួយផ្សេងទៀត ដើម្បីឱ្យមន្ត្រីនោះធ្វើសកម្មភាព ឬមិនធ្វើសកម្មភាពនៅក្នុងអនុវត្តន៍កាតព្វកិច្ចជាផ្លូវការរបស់ខ្លួន ។

(ខ) ការស្នើរសុំ ឬការទទួលយកដោយមន្ត្រីសាធារណៈម្នាក់ ដោយផ្ទាល់ ឬដោយប្រយោលនូវអត្ថប្រយោជន៍ដោយខុសច្បាប់មួយ សំរាប់មន្ត្រីនោះ ឬបុគ្គលម្នាក់ ឬអង្គភាពមួយផ្សេងទៀតដើម្បីឱ្យមន្ត្រីនោះធ្វើសកម្មភាព ឬមិនធ្វើសកម្មភាពនៅក្នុងការអនុវត្តន៍កាតព្វកិច្ចជាផ្លូវការរបស់ខ្លួន ។

២- រដ្ឋភាគីនិមួយៗ ត្រូវតែពិចារណាអំពីការអនុម័តវិធានការផ្នែកនីតិបញ្ញត្តិបែបនេះ និងវិធានការផ្សេងៗទៀត ដែលអាចមានការចាំបាច់ ដើម្បីកំណត់ជាបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើទាំងឡាយណាដែលបានលើកឡើងនៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ដែលពាក់ព័ន្ធជាមួយនឹងមន្ត្រីសាធារណៈបរទេសម្នាក់ ឬមន្ត្រីរាជការអន្តរជាតិម្នាក់ ។ ដូចគ្នានេះដែរ រដ្ឋភាគីនិមួយៗ ត្រូវតែពិចារណាអំពីការកំណត់ឱ្យមានជាបទល្មើសព្រហ្មទណ្ឌ ចំពោះរូបភាពផ្សេងៗទៀតនៃអំពើពុករលួយ ។

៣- រដ្ឋភាគីនិមួយៗ ត្រូវតែអនុម័តផងដែរនូវវិធានការចាំបាច់ ដើម្បីកំណត់ថាជាបទល្មើសព្រហ្មទណ្ឌចំពោះការចូលរួមធ្វើជាអ្នកសមគំនិតគ្នាម្នាក់នៅក្នុងបទល្មើសណាមួយដែល បានកំណត់ឡើងស្របតាមមាត្រានេះ ។

៤- ក្នុងគោលបំណងរបស់កថាខណ្ឌទី ១ នៃមាត្រានេះ និងមាត្រា ៩ នៃអនុសញ្ញានេះ ពាក្យ "មន្ត្រីសាធារណៈ" ត្រូវមានន័យថាជាមន្ត្រីសាធារណៈម្នាក់ ឬបុគ្គលម្នាក់ ដែលផ្តល់សេវាកម្មសាធារណៈមួយ ដូចបានកំណត់នៅក្នុងច្បាប់ក្នុងស្រុក និងដូចបានអនុវត្តនៅក្នុងច្បាប់ព្រហ្មទណ្ឌរបស់រដ្ឋភាគីដែលជាទីកន្លែងដែលបុគ្គលមានបញ្ហានេះ អនុវត្តមុខងារនោះ ។

## មាត្រា ៩

## វិធានការដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយៈ

១- បន្ថែមលើវិធានការទាំងឡាយ ដែលមានចែងនៅក្នុងមាត្រា ៨ នៃអនុសញ្ញានេះ រដ្ឋភាគីនិមួយៗ ត្រូវតែអនុម័ត តាមការសមស្រប និងដោយស្របតាមប្រព័ន្ធច្បាប់របស់ខ្លួន វិធានការផ្នែកនីតិបញ្ញត្តិ វិធានការដ៏មានប្រសិទ្ធិភាពផ្នែករដ្ឋបាល ឬ វិធានការផ្សេងៗទៀត ដើម្បីលើកកំពស់បូរណភាព និងដើម្បីទប់ស្កាត់ ស្វែង រកឱ្យឃើញ និងផ្តន្ទាទោសអំពើពុករលួយរបស់មន្ត្រីសាធារណៈទាំងឡាយ ។

២- រដ្ឋភាគីនិមួយៗ ត្រូវតែចាត់វិធានការទាំងឡាយ ដើម្បីធានាឱ្យអាជ្ញាធររបស់ខ្លួនអាចធ្វើសកម្មភាពប្រកបដោយ ប្រសិទ្ធិភាព នៅក្នុងការទប់ស្កាត់ ការស្វែងរក និង ការផ្តន្ទាទោសអំពើពុករលួយរបស់មន្ត្រីសាធារណៈទាំងឡាយ ដោយរាប់ទាំងការផ្តល់ឱ្យអាជ្ញាធរនេះនូវឯករាជ្យភាពគ្រប់គ្រាន់ ដើម្បីរារាំងដល់ការដាក់ជាបន្ថែមនូវឥទ្ធិពលមិនសមស្របទៅលើ សកម្មភាពរបស់ខ្លួន ។

## មាត្រា ១០

## ការទទួលខុសត្រូវរបស់នីតិបុគ្គលៈ

១- រដ្ឋភាគីនិមួយៗ ត្រូវតែអនុម័តវិធានការទាំងឡាយ ដែលអាចមានការចាំបាច់ ស្របទៅតាមគោលការណ៍ច្បាប់របស់ខ្លួន ដើម្បីបង្កើតឱ្យមានការទទួលខុសត្រូវរបស់នីតិបុគ្គល ចំពោះការចូលរួមនៅក្នុងបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរ ដែលពាក់ព័ន្ធជាមួយនឹងក្រុមបណ្តាញឧក្រិដ្ឋជនមួយក្រុម និងចំពោះបទល្មើស ទាំងឡាយ ដែលត្រូវបានកំណត់ឡើងស្របតាមមាត្រា ៥ មាត្រា ៦ មាត្រា ៨ និងមាត្រា ២៣ នៃអនុសញ្ញា នេះ ។

២- លើកលែងតែមានការចែងផ្សេងដោយគោលការណ៍ច្បាប់របស់រដ្ឋភាគី ការទំនួលខុសត្រូវរបស់នីតិបុគ្គលអាចជាព្រហ្មទណ្ឌ ជារដ្ឋប្បវេណី ឬជាផ្នែករដ្ឋបាល ។

៣- ទំនួលខុសត្រូវបែបនេះ ត្រូវតែបានដាក់ឱ្យអនុវត្តដោយដាច់ដោយឡែកអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់រូបវន្តបុគ្គល ដែលបានប្រព្រឹត្តបទល្មើស។

៤- រដ្ឋភាគីនិមួយៗ ត្រូវតែធានា ជាពិសេស ថានីតិបុគ្គលទាំងឡាយ ត្រូវតែធានា ថានីតិបុគ្គលដែល ជាអ្នកទទួលខុសត្រូវស្របតាមមាត្រា នេះ ត្រូវបានជាកម្មវត្ថុនៃទណ្ឌកម្មព្រហ្មទណ្ឌប្រកបដោយ ប្រសិទ្ធិភាពដោយសមាមាត្រ និងមានលក្ខណះបង្ក្រាបផ្នែកព្រហ្មទណ្ឌ ឬ មិនមែនព្រហ្មទណ្ឌ ដោយរាប់ទាំងទណ្ឌកម្មជាប្រាក់ផងដែរ។

## មាត្រា ១១

### ការចោទប្រកាន់ សាលក្រមប្រកាសផ្តន្ទាទោស និងទណ្ឌកម្ម:

១- រដ្ឋភាគីនិមួយៗ ត្រូវតែធ្វើឱ្យការប្រព្រឹត្តិបទល្មើសមួយ ដែលត្រូវបានកំណត់ឡើងស្របតាមមាត្រា ៥ មាត្រា ៦ មាត្រា ៨ និងមាត្រា ២៣ នៃអនុសញ្ញានេះ ទទួលរងទណ្ឌកម្មទាំងឡាយ ដោយពិចារណាអំពីកំរិតធ្ងន់ ឬស្រាលនៃបទល្មើសនោះ ។

២- រដ្ឋភាគីនិមួយៗ ត្រូវតែខិតខំប្រឹងប្រែងធានាថា អំណាចយុត្តាធិការប្រកបដោយឆន្ទានុសិទ្ធិណាមួយដែលផ្តល់ដោយនីតិក្នុងស្រុករបស់ខ្លួន និងដែលទាក់ទងជាមួយនឹងការចោទប្រកាន់បុគ្គលទាំងឡាយចំពោះបទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ ត្រូវបានអនុវត្តឡើង ដើម្បីពង្រឹងប្រសិទ្ធិភាពឱ្យបានជាអតិបរមា នូវវិធានការណ៍នានាសំរាប់ស្វែងរក និងបង្ក្រាបបទល្មើសទាំងនោះ ដោយមានតំរូវការត្រឹមត្រូវតាមច្បាប់ ដើម្បីរារាំងដល់ការប្រព្រឹត្តិបទល្មើសបែបនោះ។

៣- ចំពោះបទល្មើសនានា ដែលត្រូវបានកំណត់ឡើងស្របតាមមាត្រា ៥ មាត្រា ៦ មាត្រា ៨ និង មាត្រា ២៣ នៃអនុសញ្ញានេះ រដ្ឋភាគីនិមួយៗ ត្រូវតែចាត់វិធានការសមស្របនានា ស្របតាមច្បាប់ ក្នុងស្រុករបស់ខ្លួន និង ដោយមានសិទ្ធិត្រឹមត្រូវក្នុងការការពារ ដើម្បីស្វះស្វែងរកការធានាថា លក្ខខណ្ឌទាំងឡាយ ដែលបានដាក់ ទាក់ទងជាមួយនឹងសេចក្តីសំរេចនានាស្តីពីការដោះលែងដោយរងចាំ ការជំនុំជំរះក្តី ឬការប្តឹងឧទ្ធរណ៍ពិចារណាអំពីតំរូវការដើម្បីធានាឱ្យមានវត្តមានភាគីចុងចោទនៅឯ ដំណាក់ការជំនុំជំរះក្តីព្រហ្មទណ្ឌដែលនឹងកើតឡើងនៅពេលបន្ទាប់មកទៀត ។

៤- រដ្ឋភាគីនិមួយៗ ត្រូវតែធានាថា តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀតរបស់ខ្លួន ត្រូវតែបានគិតគូរអំពីចរិតលក្ខណៈធ្ងន់ធ្ងរនៃបទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ នៅពេលពិចារណាអំពីលទ្ធភាពនៃការដោះលែងជាមុន ឬការដោះលែងដោយមានលក្ខខណ្ឌចំពោះ បុគ្គលទាំងឡាយ ដែលត្រូវបានប្រកាសថាបានប្រព្រឹត្តបទល្មើសទាំងនេះ ។

៥- ក្នុងករណីសមស្រប រដ្ឋភាគីនិមួយៗ ត្រូវតែបង្កើត នៅក្នុងច្បាប់ក្នុងស្រុករបស់ខ្លួន នូវអាជ្ញាយុកាលដែលមានរយះពេលវែងមួយ ដែលនៅក្នុងរយះពេលនេះ ការចោទប្រកាន់ចំពោះបទល្មើសណាមួយ ដែលមានចែងនៅក្នុងអនុ សញ្ញានេះអាចធ្វើបាន។ រយះពេលនេះនឹងយូរជាងនេះ ក្នុងករណីដែលជនល្មើសដែលត្រូវបានអះអាងនោះ បានគេចចេញផុតពី រដ្ឋបាលយុត្តិធម៌ ។

៦- គ្មានបទបញ្ញត្តិណាមួយនៅក្នុងអនុសញ្ញានេះ មានផលប៉ះពាល់ទៅលើគោលការណ៍ ដែលចែងថា ការកំណត់បទល្មើសទាំងឡាយត្រូវធ្វើឡើងស្របតាមអនុសញ្ញានេះ និងការកំណត់ពីមធ្យោបាយការពារ តាមផ្លូវច្បាប់ដែលអាចអនុវត្តន៍បាន ឬការកំណត់គោលការណ៍ច្បាប់នានាផ្សេងទៀតដែលគ្រប់គ្រងការ ប្រព្រឹត្តិតាមផ្លូវច្បាប់ត្រូវទុកជាសមត្ថកិច្ចនៃច្បាប់ក្នុងស្រុករបស់រដ្ឋភាគី និង និងគោលការណ៍ដែលបទ ល្មើសទាំងនេះ ត្រូវតែចោទ ប្រកាន់ និងផ្តន្ទាទោសស្របតាមច្បាប់នោះ ។

## មាត្រា ១២

**ការដកហូត និងការរឹបអូស:**

១- រដ្ឋភាគីទាំងឡាយ ត្រូវតែអនុម័ត តាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន នៅក្នុងប្រព័ន្ធ ច្បាប់ក្នុងស្រុករបស់ខ្លួន នូវវិធានការទាំងឡាយដែលចាំបាច់ ដើម្បីអាចដកហូតនូវៈ

(ក) ផលនៃអំពើឧក្រិដ្ឋ ដែលបានមកពីបទល្មើសទាំងឡាយ ដែលកំណត់ដោយអនុសញ្ញានេះ ឬទ្រព្យសម្បត្តិ ដែលមានតំលៃសមមូលនឹងផលនៃអំពើឧក្រិដ្ឋកម្មនេះ

(ខ) ទ្រព្យសម្បត្តិ បរិក្ខារ ឬសំភារះផ្សេងៗទៀត ដែលត្រូវបានប្រើប្រាស់ ឬបំរុងនឹងប្រើប្រាស់នៅក្នុង បទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ ។

២- រដ្ឋភាគីទាំងឡាយ ត្រូវតែអនុម័តនូវវិធានការទាំងឡាយដែលចាំបាច់ សំរាប់អាចកំណត់អត្តសញ្ញាណ កំណត់ទីតាំង បង្ខាំងទុក ឬរឹបអូសទ្រព្យសម្បត្តិណាមួយ ដែលបាននិយាយសំដៅនៅ ក្នុងកថាខណ្ឌ ទី ១ នៃមាត្រានេះ ដើម្បីធ្វើការដកហូតជាយថាហេតុ ។

៣- ប្រសិនបើផលពីការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្មនេះ ត្រូវបានផ្លាស់ប្តូរ ឬបានកែប្រែមួយផ្នែក ឬទាំងស្រុង ទៅជាទ្រព្យសម្បត្តិផ្សេងទៀតនោះ ទ្រព្យសម្បត្តិទាំងនេះ ត្រូវតែស្ថិតនៅក្រោមវិធានការទាំងឡាយ ដែលបាននិយាយសំដៅនៅក្នុងមាត្រានេះ ដោយជំនួសផលពីការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្មនេះវិញ ។

៤- ប្រសិនបើផលពីការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្មនេះ ត្រូវបានលាយគ្នាជាមួយនឹងទ្រព្យសម្បត្តិ ដែលបានមកដោយស្របច្បាប់ ទ្រព្យសម្បត្តិបែបនេះ ត្រូវតែស្ថិតនៅក្រោមការរឹបអូសយកក្នុងចំនួន រហូតដល់តំលៃដែលបានប៉ាន់ស្មាននៃផលដែលត្រូវបានលាយនោះ ដោយមិនគិតដល់អំណាចណាមួយ ដែលទាក់ទងជាមួយនឹងការបង្ខាំងទុក ឬការរឹបអូសយកនោះទេ ។

៥- ប្រាក់ចំណូល ឬផលប្រយោជន៍ផ្សេងៗទៀត ដែលបានមកពីប្រាក់ចំណូលពីការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្ម ដែលបានមកពីទ្រព្យសម្បត្តិ ដែលចេញមកពីការផ្លាស់ប្តូរ ឬ ការកែប្រែផលនៃការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្ម ដែលបានលាយគ្នានោះ ត្រូវតែស្ថិតនៅក្រោមវិធានការទាំងឡាយ ដែលបាននិយាយសំដៅនៅក្នុងមាត្រា នេះ ក្នុងលក្ខណៈ និងទំហំដូចគ្នានឹងផលពីការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្មនោះផងដែរ ។

៦- សំរាប់គោលបំណងរបស់មាត្រានេះ និងមាត្រា ១៣ នៃអនុសញ្ញានេះ រដ្ឋភាគីនិមួយៗ ត្រូវតែផ្តល់សិទ្ធិ អំណាចដល់តុលាការ និងអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀតរបស់ខ្លួន ដើម្បីបញ្ជាឱ្យមាន ការផលិត ឬ ការរឹបអូស ឯកសារធនាគារ ឯកសារហិរញ្ញវត្ថុ ឬឯកសារពាណិជ្ជកម្មផ្សេងៗ។ រដ្ឋភាគីទាំងឡាយ មិនអាចលើកសំអាងពីភាពសំងាត់របស់ធនាគារដើម្បីគេចវេះពីការធ្វើសកម្មភាពតាមបទបញ្ញត្តិនៃ កថាខណ្ឌនេះឡើយ ។

៧- រដ្ឋភាគីទាំងឡាយ អាចពិចារណាអំពីលទ្ធភាព ដែលតំរូវឱ្យអ្នកប្រព្រឹត្តបទល្មើស បង្ហាញនូវ ប្រភពដើមត្រឹមត្រូវតាមច្បាប់នៃផលដែលត្រូវបានសន្មត់ថាបានកមមកអំពើឧក្រិដ្ឋកម្មនោះ ឬទ្រព្យសម្បត្តិផ្សេងៗទៀត ដែលអាចធ្វើជាកម្មវត្ថុនៃការដកហូត ក្នុងទំហំដែលការតំរូវនោះមាន លក្ខណៈសមស្របតាមគោលការណ៍ទាំងឡាយនៃច្បាប់ក្នុងស្រុករបស់ខ្លួន និងតាមប្រភេទនៃនីតិវិធីតុលាការ និងនីតិវិធីផ្សេងៗទៀត ។

៨- ការបកស្រាយបទបញ្ញត្តិទាំងឡាយនៃមាត្រានេះមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សិទ្ធិនៃតតីយជនសុច្ចរិតឡើយ ។

៩- គ្មានបទបញ្ញត្តិណាមួយនៅក្នុងមាត្រានេះ នឹងមានផលប៉ះពាល់ទៅលើគោលការណ៍ទាំងឡាយ ដែលថាវិធានការទាំងឡាយ ដែលបាននិយាយសំដៅនោះ ត្រូវតែបានកំណត់ និងត្រូវបានអនុវត្តន៏ស្របតាមបទបញ្ញត្តិទាំងឡាយនៃច្បាប់ក្នុងស្រុករបស់រដ្ឋភាគីមួយនោះទេ ។

## មាត្រា ១៣

## កិច្ចសហប្រតិបត្តិការអន្តរជាតិ សំរាប់គោលបំណងនៃការដកហូត

១- ក្នុងទំហំទូលំទូលាយបំផុតតាមដែលអាចធ្វើទៅបាននៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុករបស់ខ្លួន រដ្ឋភាគីមួយបន្ទាប់ពីបានទទួលសំណើរពីរដ្ឋភាគីមួយផ្សេងទៀតដែលមានដែនសមត្ថកិច្ចលើបទល្មើសមួយដែលមានចែងនៅក្នុងអនុសញ្ញានេះ សំរាប់ការដកហូតផលនៃអំពើឧក្រិដ្ឋកម្ម ទ្រព្យសម្បត្តិ បរិក្ខារ ឬលិខិតុបករណ៍ផ្សេងៗទៀត ដែលបាននិយាយសំដៅនៅក្នុងមាត្រា ១២ កថាខណ្ឌ ទី ១ នៃអនុសញ្ញានេះ ដែលតាំងនៅក្នុងទឹកដីរបស់ខ្លួន ត្រូវតែ:

(ក) បញ្ជូនសំណើរនោះទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន សំរាប់គោលបំណងនៃការទទួលបាននូវបទបញ្ជាមួយដើម្បីដកហូត ហើយប្រសិនបើបទបញ្ជាមួយបែបនេះ ត្រូវបានផ្តល់ឱ្យត្រូវអនុវត្តបទបញ្ជានោះ ឬ

(ខ) បញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីឱ្យមានការអនុវត្ត ទៅតាមកំរិតនៃការស្នើសុំបទបញ្ជាដើម្បីដកហូតដែលបានចេញដោយតុលាការមួយនៅក្នុងទឹកដីរបស់រដ្ឋភាគីដែលបានស្នើសុំនោះស្របតាមមាត្រា ១២ កថាខណ្ឌទី ១ នៃអនុសញ្ញានេះ ដែលទាក់ទង នឹងផលពីការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្ម ទ្រព្យសម្បត្តិ បរិក្ខារ ឬលិខិតុបករណ៍ផ្សេងៗទៀត ដែលបាននិយាយសំដៅនៅក្នុងមាត្រា ១២ កថាខណ្ឌទី ១ ដែលតាំងនៅក្នុងទឹកដីរបស់រដ្ឋភាគីដែល ត្រូវបានស្នើសុំនោះ ។

២- បន្ទាប់ពីមានសំណើរមួយ ដែលបានធ្វើឡើងដោយរដ្ឋភាគីមួយផ្សេងទៀត ដែលមានដែនសមត្ថកិច្ចលើបទល្មើសមួយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ រដ្ឋភាគីដែលត្រូវបានស្នើសុំនោះ ត្រូវតែចាត់វិធានការនានា ដើម្បីរកឱ្យឃើញ តាមដាន និងបង្ខាំងទុក ឬរឹបអូសយកប្រាក់ចំណូលពីការប្រព្រឹត្តិអំពើឧក្រិដ្ឋ កម្មទ្រព្យសម្បត្តិ បរិក្ខារ ឬលិខិតុបករណ៍ផ្សេងៗទៀត ដែលបាននិយាយសំដៅនៅក្នុងមាត្រា ១២ កថាខណ្ឌទី ១ នៃអនុសញ្ញានេះ សំរាប់ធ្វើការដកហូតជាយថាហេតុ ដែលត្រូវបានបញ្ជាដោយ

រដ្ឋភាគីដែលបានស្នើសុំ ស្របទៅតាមសំណើរមួយដែលអនុលោមតាមកថាខណ្ឌទី ១ នៃមាត្រានេះ ឬដោយរដ្ឋភាគី ដែលត្រូវបានស្នើសុំនោះ ។

៣- បទបញ្ញត្តិនៅក្នុងមាត្រា ១៨ នៃអនុសញ្ញានេះ អាចអនុវត្តបានចំពោះមាត្រានេះ បើមានការចាំបាច់ (mutatis mutadis) ។ បន្ថែមលើពត៌មាន ដែលបានបញ្ជាក់នៅក្នុងមាត្រា ១៨ កថាខណ្ឌទី ១៥ សំណើរទាំងឡាយដែលបានធ្វើឡើងស្របទៅតាម មាត្រានេះ ត្រូវមាន :

(ក) ក្នុងករណីដែលសំណើរជាប់ទាក់ទងជាមួយនឹងកថាខណ្ឌទី ១ ចំនុច (ក) នៃមាត្រានេះ សេចក្តីពិពណ៌នាមួយអំពីទ្រព្យសម្បត្តិ ដែលត្រូវដកហូត និងសេចក្តីថ្លែងការណ៍មួយអំពីអង្គហេតុ ដែលជាមូលដ្ឋាននៃការស្នើសុំរបស់រដ្ឋភាគីដែលមានលក្ខណៈគ្រប់គ្រាន់ដើម្បីឱ្យរដ្ឋភាគី ដែលត្រូវបានស្នើសុំ អាចស្វះស្វែងរកបទបញ្ជានោះអនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួនបាន

(ខ) ក្នុងករណីដែលសំណើរមួយ ដែលជាប់ទាក់ទងជាមួយនឹងកថាខណ្ឌទី ១ ចំនុច (ខ) នៃមាត្រានេះ ច្បាប់ចំលងមួយនៃបទបញ្ជាដកហូតមួយ ដែលអាចទទួលបានតាមផ្លូវច្បាប់ ដែលបានចេញដោយរដ្ឋភាគីដែលបានស្នើសុំសេចក្តីថ្លែងការណ៍មួយអំពីអង្គហេតុ និង ពត៌មានកំនត់ទំហំនៃការអនុវត្តន៍ ដែលត្រូវតែបានស្នើសុំឡើងចំពោះបទបញ្ជា

(គ) ក្នុងករណីដែលសំណើរមួយដែលជាប់ទាក់ទងជាមួយនឹងកថាខណ្ឌទី ២ នៃមាត្រានេះ សេចក្តីថ្លែងការណ៍មួយអំពីអង្គសហេតុដែលជាមូលដ្ឋាននៃការស្នើសុំនៃរដ្ឋភាគី និងសេចក្តីពិពណ៌នាមួយអំពីសកម្មភាព ត្រូវតែបានស្នើសុំឡើង ។

៤- សេចក្តីសំរេច ឬសកម្មភាពទាំងឡាយ ដែលបានចែងនៅក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃមាត្រានេះ ត្រូវធ្វើឡើងដោយភាគីដែលត្រូវបានស្នើសុំ ឱ្យស្របតាម បទបញ្ញត្តិទាំងឡាយនៃច្បាប់ក្នុងស្រុករបស់ខ្លួន និង ទៅតាមបញ្ញាតិនៃច្បាប់នេះ និង វិធាននីតិវិធីរបស់ខ្លួន ឬសន្ធិសញ្ញា ឬកិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងទ្វេភាគី ឬពហុភាគី ដែលអាចមានការទាក់ទងជាមួយនឹងរដ្ឋភាគីដែលបានស្នើសុំ នោះ ។

៥- រដ្ឋភាគីនិមួយៗ ត្រូវតែផ្តល់ច្បាប់ចំលងនៃច្បាប់របស់ខ្លួន និង បទបញ្ជាទាំងឡាយ ដែលផ្តល់អានុភាពមានដល់មាត្រានេះ និង ច្បាប់ចំលងនៃសេចក្តីកែប្រែទាំងឡាយណាមួយនៅពេលបន្ទាប់មកទៀតចំពោះច្បាប់ និង បទបញ្ជាទាំងឡាយនេះ ឬសេចក្តីពិពណ៌នាមួយនៃច្បាប់ និង សេចក្តីកែប្រែនេះជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៦- ប្រសិនបើរដ្ឋភាគីមួយ ធ្វើការសំរេចចិត្តលៃយកវិធានការទាំងឡាយ ដែលបាននិយាយសំដៅនៅក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃមាត្រានេះ ដោយមានសន្ធិសញ្ញាមួយចំពោះរឿងនេះ រដ្ឋភាគីនោះ ត្រូវតែចាត់ទុកអនុសញ្ញានេះថាជាសន្ធិសញ្ញាជាមូលដ្ឋាន ដែលមានភាពចាំបាច់ និងគ្រប់គ្រាន់ ។

៧- កិច្ចសហប្រតិបត្តិការនៅក្រោមមាត្រានេះ អាចត្រូវបានបដិសេធដោយរដ្ឋភាគីមួយ ប្រសិនបើបទល្មើសដែលមានការពាក់ព័ន្ធជាមួយនឹងសំណើរនោះ មិនមែនជាបទល្មើសមួយ ដែលមានចែងនៅក្នុងអនុសញ្ញានេះទេនោះ ។

៨- បទបញ្ញត្តិទាំងឡាយនៃមាត្រានេះ មិនត្រូវមានការបកស្រាយធ្វើអោយប៉ះពាល់ដល់ សិទ្ធិនៃតតិយជនសុចរិត នោះទេ ។

៩- រដ្ឋភាគីទាំងឡាយ ត្រូវតែពិចារណាអំពីការចុះសន្ធិសញ្ញា ឬកិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងទ្វេ ភាគី ឬពហុភាគី ដើម្បីធ្វើឱ្យប្រសើរឡើងដល់ប្រសិទ្ធិភាពនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលត្រូវបានចាត់ធ្វើឡើងស្របតាមមាត្រានេះ ។

## មាត្រា ១៤

**ការកាន់កាប់ប្រើប្រាស់ផលិតផលអំពើឧក្រិដ្ឋកម្ម ឬទ្រព្យសម្បត្តិ ដែលបានដកហូតៈ**

១- ផលិតផលអំពើឧក្រិដ្ឋកម្ម ឬទ្រព្យសម្បត្តិ ដែលបានដកហូតដោយរដ្ឋភាគីមួយ ស្របតាម មាត្រា ១២ ឬមាត្រា ១៣ កថាខណ្ឌទី ១ នៃអនុសញ្ញានេះ ត្រូវកាន់កាប់ប្រើប្រាស់ដោយរដ្ឋភាគីនោះ ស្របតាមច្បាប់ក្នុងស្រុក និងនីតិវិធីផ្នែករដ្ឋបាលរបស់ខ្លួន ។

២- នៅពេលធ្វើសកម្មភាពតាមសំណើរ ដែលបានធ្វើឡើងដោយរដ្ឋភាគីមួយផ្សេងទៀត ស្របតាមមាត្រា ១៣ នៃអនុសញ្ញានេះ រដ្ឋភាគីទាំងអស់ ត្រូវតែផ្តល់ការពិចារណាជាអាទិភាពដើម្បីប្រគល់ផលិតផលអំពើឧក្រិដ្ឋកម្ម ឬទ្រព្យសម្បត្តិ ដែលបានដកហូតនោះ ទៅឱ្យរដ្ឋភាគីដែលបានស្នើសុំនោះ វិញ ទៅតាមការអនុញ្ញាតដោយច្បាប់ក្នុងស្រុក និងប្រសិនបើមានការស្នើសុំ ដើម្បីអោយរដ្ឋភាគីដែលបានស្នើសុំនោះ អាចផ្តល់ការសង ជំងឺចិត្តជូនទៅជនរងគ្រោះដោយសារអំពើឧក្រិដ្ឋកម្មនោះ ឬប្រគល់ប្រាក់ចំណូលពីការប្រព្រឹត្តិអំពើឧក្រិដ្ឋ កម្ម ឬទ្រព្យសម្បត្តិបែបនោះ ទៅឱ្យម្ចាស់ស្របច្បាប់ដើមវិញ ។

៣- នៅពេលធ្វើសកម្មភាពតាមសំណើរ ដែលបានធ្វើឡើងដោយរដ្ឋភាគីមួយផ្សេងទៀត ស្របតាមមាត្រា ១២ និងមាត្រា ១៣ នៃអនុសញ្ញានេះ រដ្ឋភាគីមួយ អាចផ្តល់ការពិចារណាជាពិសេសអំពីការចុះកិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងទាំងឡាយស្តីពីៈ

(ក) ការផ្ទេរតំលៃនៃផលិតផលអំពើឧក្រិដ្ឋកម្ម ឬទ្រព្យសម្បត្តិ ឬមូល និធិបែបនេះ ដែលបានមកពីការលក់ផលិតផល អំពើឧក្រិដ្ឋកម្ម ឬទ្រព្យសម្បត្តិ ឬផ្នែកណាមួយនៃទ្រព្យសម្បត្តិបែបនោះ ទៅកាន់គណនី ដែលបានបង្កើតឡើង ស្របតាមមាត្រា ៣០ កថាខណ្ឌទី ២ ចំនុច (គ) នៃអនុសញ្ញានេះ និងទៅកាន់អង្គការអន្តរដ្ឋាភិបាលទាំងឡាយ ដែលមានជំនាញខាងការប្រយុទ្ធប្រឆាំងនឹងបណ្តាញអំពើឧក្រិដ្ឋកម្ម ។

(ខ) ការចែករំលែកជាមួយនឹងរដ្ឋភាគីផ្សេងៗទៀត ជាស្វ័យប្រវត្ត ឬមួយករណីម្តងៗ នូវប្រាក់ចំណូលពីការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្ម ឬទ្រព្យសម្បត្តិ ឬមូលនិធិបែបនេះ ដែលបានមកពីការផលិតផលអំពើឧក្រិដ្ឋកម្ម ឬទ្រព្យសម្បត្តិបែបនេះ ស្របតាមច្បាប់ក្នុងស្រុក ឬនីតិវិធីផ្នែករដ្ឋបាលរបស់ខ្លួន ។

## មាត្រា ១៥

**ដែនសមត្ថកិច្ចៈ**

១- រដ្ឋភាគីនិមួយៗ ត្រូវតែអនុម័តវិធានការទាំងឡាយបែបនេះ ដែលចាំបាច់ ដើម្បីបង្កើតឡើងនូវដែនសមត្ថកិច្ចរបស់ខ្លួនចំពោះបទល្មើសទាំងឡាយ ដែលបានបង្កើតឡើងស្របតាមមាត្រា ៥ មាត្រា ៦ មាត្រា ៨ និងមាត្រា ២៣ នៃអនុសញ្ញានេះ ក្នុងករណីដូចខាងក្រោម :

(ក) នៅពេលដែល បទល្មើសនោះ ត្រូវបានប្រព្រឹត្តនៅក្នុងទឹកដីរបស់ខ្លួន ឬ

(ខ) បទល្មើសនោះ ត្រូវបានប្រព្រឹត្តនៅលើនាវាមួយគ្រឿង ដែលមានដាក់ទង់ជាតិរបស់ខ្លួន ឬនៅលើយន្តហោះមួយគ្រឿង ដែលបានចុះបញ្ជីនៅក្រោមច្បាប់របស់ខ្លួន នៅក្នុងរយៈពេលដែលបទល្មើសនោះ ត្រូវបានប្រព្រឹត្ត ។

២- លើកលែងតែបញ្ញាតិនៃមាត្រា៤ នៃអនុសញ្ញានេះ រដ្ឋភាគីមួយ ក៏អាចបង្កើតឡើងនូវដែនសមត្ថកិច្ចរបស់ខ្លួនផងដែរ ចំពោះបទល្មើសណាមួយបែបនេះ ក្នុងករណីដូចខាងក្រោម :

(ក) បទល្មើសនោះ ត្រូវបានប្រព្រឹត្តដើម្បីអនិកជនម្នាក់របស់ខ្លួន

(ខ) បទល្មើសនោះ ត្រូវបានប្រព្រឹត្តដោយអនិកជនម្នាក់របស់ខ្លួន ឬដោយបុគ្គលម្នាក់គ្មាន រដ្ឋ ដែលមានលំនៅដ្ឋាននៅក្នុងទឹកដីរបស់ខ្លួន

(គ) បទល្មើសនោះ គឺជា:

(១) បទល្មើសមួយក្នុងចំណោមបទល្មើសទាំងឡាយ ដែលបានបង្កើតឡើងស្របតាមមាត្រា ៥ កថាខណ្ឌទី ១ នៃអនុសញ្ញានេះ ត្រូវបានប្រព្រឹត្តនៅក្រៅទឹកដីរបស់ខ្លួន ដើម្បីប្រព្រឹត្តិបទល្មើស ព្រហ្មទណ្ឌធ្ងន់ធ្ងរនៅក្នុងទឹកដីរបស់ខ្លួន

(២) បទល្មើសមួយក្នុងចំណោមបទល្មើសទាំងឡាយ ដែលបានបង្កើតឡើងស្របតាមមាត្រា ៦ កថាខណ្ឌទី ១ ចំនុច (ខ) ចំនុច (២) នៃអនុសញ្ញានេះ និងត្រូវបានប្រព្រឹត្តនៅក្រៅទឹកដីរបស់ខ្លួន ដើម្បីប្រព្រឹត្តិបទល្មើសមួយ ដែលបានបង្កើតឡើងស្របតាមមាត្រា ៦ កថាខណ្ឌទី ១ ចំនុច (ក) ចំនុច (១) ឬចំនុច (២) ឬចំនុច (ខ) ចំនុច (១) នៃអនុសញ្ញា នេះ នៅក្នុងទឹក ដីរបស់ខ្លួន ។

៣- សំរាប់គោលបំណងរបស់មាត្រា ១៦ កថាខណ្ឌទី ១០ នៃអនុសញ្ញានេះ រដ្ឋភាគីនិមួយៗ ត្រូវតែអនុម័ត វិធានការចាំបាច់ទាំងឡាយ ដើម្បីបង្កើតឡើងនូវដែនសមត្ថកិច្ចរបស់ខ្លួន ចំពោះបទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ នៅពេលដែលអ្នកប្រព្រឹត្តបទល្មើសម្នាក់ ដែលត្រូវបានចោទប្រកាន់នោះ ស្ថិតនៅលើទឹកដីរបស់ខ្លួន ហើយខ្លួនមិនបានធ្វើបត្យាប័នបុគ្គល នោះ ដោយសារមានមូលហេតុតែមួយគត់ថាបុគ្គលនោះ គឺជាអណិកជនម្នាក់របស់ខ្លួន ។

៤- រដ្ឋភាគីនិមួយៗ ក៏អាចអនុម័តវិធានការចាំបាច់ទាំងឡាយ ដើម្បី បង្កើតឡើងនូវដែនសមត្ថកិច្ចរបស់ខ្លួន ចំពោះបទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ នៅពេលដែលអ្នកប្រព្រឹត្តបទល្មើសម្នាក់ ដែលត្រូវបានចោទប្រកាន់នោះ ស្ថិតនៅលើទឹកដីរបស់ខ្លួន ហើយខ្លួន មិនធ្វើបត្យាប័នបុគ្គលនោះទេ ។

៥- ប្រសិនបើរដ្ឋភាគីមួយ ដែលអនុវត្តន៍ដែនសមត្ថកិច្ចរបស់ខ្លួននៅក្រោមកថាខណ្ឌទី ១ ឬកថាខណ្ឌទី ២ នៃ មាត្រានេះ ត្រូវបានជូនដំណឹង ឬត្រូវបានដឹងឮថា រដ្ឋភាគីមួយ ឬរដ្ឋភាគីច្រើនទៀត កំពុងតែអនុវត្តន៍ការស៊ើបអង្កេត ការចោទប្រកាន់ ឬ នីតិវិធីតុលាការមួយ ទាក់ទងនឹងរឿងតែមួយ អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីទាំងនោះ ត្រូវតែពិគ្រោះយោបល់គ្នា តាមការសមស្របក្នុងលក្ខណៈ ដើម្បីធ្វើការសំរបសំរួលសកម្មភាពរបស់ខ្លួន ។

៦- ដោយមិនបង្ករព្យសនកម្មដល់បទដ្ឋានទាំងឡាយនៃច្បាប់អន្តរជាតិជាទូទៅ អនុសញ្ញានេះ មិនបានទាត់ចោលការអនុវត្តនីដែនសមត្ថកិច្ចផ្នែកព្រហ្មទណ្ឌណាមួយ ដែលបានបង្កើតឡើងដោយរដ្ឋភាគីមួយស្របតាមច្បាប់ក្នុងស្រុករបស់ខ្លួននោះទេ ។

## មាត្រា ១៦

## បត្យាប័នៈ

១- មាត្រានេះ ត្រូវតែអនុវត្តនីចំពោះបទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ ឬក្នុងករណីដែលបទល្មើសមួយ ត្រូវបាននិយាយសំដៅនៅក្នុងមាត្រា ៣ កថាខណ្ឌទី ១ ចំនុច (ក) ឬចំនុច (ខ) ហើយបុគ្គលដែលជាកម្មវត្ថុនៃសំណើរធ្វើបត្យាប័នស្ថិតនៅក្នុងទឹកដីរបស់រដ្ឋភាគីដែលត្រូវបានស្នើសុំដរាបណាបទល្មើស ដែលត្រូវសុំធ្វើបត្យាប័ននោះ ត្រូវបានផ្តន្ទាទោសនៅក្រោមច្បាប់ក្នុងស្រុកនៃរដ្ឋភាគីទាំងពីរ មានន័យថា ទាំងរដ្ឋភាគី ដែលបានស្នើសុំ និងរដ្ឋភាគីដែលត្រូវបានស្នើសុំនោះ ។

២- ប្រសិនបើសំណើរធ្វើបត្យាប័ននេះ ធ្វើឡើងចំពោះបទល្មើសព្រហ្មទណ្ឌច្រើនដាច់ដោយឡែកពីគ្នាដែលបទល្មើសព្រហ្មទណ្ឌមួយចំនួន មិនបានចែងនៅក្នុងមាត្រានេះ រដ្ឋភាគីដែលត្រូវបានស្នើសុំអាចអនុវត្តនីមា ត្រានេះផងដែរ ចំពោះបទល្មើសដែលបានលើកឡើងមកនេះ ។

៣- បទល្មើសនិមួយៗ ដែលមាត្រានេះត្រូវអនុវត្តនីទៅលើនោះ ត្រូវតែរាប់បញ្ចូលដោយពេញច្បាប់ក្នុងសន្ធិសញ្ញាធ្វើបត្យាប័នជាធរមានរវាងរដ្ឋភាគីថាជាបទល្មើស ដែលជនល្មើស ដែលជនល្មើសអាចត្រូវបានគេធ្វើបត្យាប័ន ។ រដ្ឋភាគីទាំងឡាយ ត្រូវតែសន្យាបញ្ចូលបទល្មើសទាំងនេះ ជាបទល្មើសដែលត្រូវធ្វើបត្យាប័ននៅក្នុង សន្ធិសញ្ញាធ្វើបត្យាប័នទាំងអស់ ដែលរដ្ឋភាគីទាំងនោះបានចុះជាមួយគ្នា ។

៤- ប្រសិនបើរដ្ឋភាគីមួយ ដែលដាក់ការធ្វើបត្យាប័នជាលក្ខខណ្ឌមួយអាស្រ័យតាមសន្ធិសញ្ញាបត្យាប័នមួយបានទទួល សំណើរធ្វើបត្យាប័នពីរដ្ឋភាគីមួយផ្សេងទៀត ដែលខ្លួនមិនមានសន្ធិសញ្ញាធ្វើបត្យាប័នជាមួយសោះ នោះខ្លួន អាចចាត់ទុកអនុសញ្ញានេះ ជាមូលដ្ឋានផ្លូវច្បាប់សំរាប់ការធ្វើបត្យាប័នចំពោះបទល្មើសណាមួយ ដែលមាត្រានេះ ត្រូវអនុវត្តនីទៅលើ ។

៥- រដ្ឋភាគីទាំងឡាយ ដែលដាក់ការធ្វើបត្យាប័នអាស្រ័យទៅនឹងសន្ធិសញ្ញាមួយនោះ ត្រូវតែៈ

(ក) នៅក្នុងពេលដាក់មធ្យោបាយ សំរាប់ការផ្តល់សច្ចាប័ន ការព្រមទទួលយក ការអនុម័តទទួលយក ឬការទទួលយកអនុសញ្ញានេះ ជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ថា

តើខ្លួន នឹងយកអនុសញ្ញានេះធ្វើជាមូលដ្ឋានផ្លូវច្បាប់ដែរឬទេ សំរាប់កិច្ចសហប្រតិបត្តិការអំពីការធ្វើបត្យាប័ននេះជាមួយនឹងរដ្ឋភាគីផ្សេងៗទៀតនៃអនុសញ្ញានេះ ហើយ

(ខ) ប្រសិនបើខ្លួន មិនចាត់ទុក អនុសញ្ញានេះធ្វើជាមូលដ្ឋានផ្លូវច្បាប់សំរាប់កិច្ចសហប្រតិបត្តិការអំពីការធ្វើបត្យាប័ននោះទេ ខ្លួនត្រូវតែស្វះស្វែងរក តាមការសមស្រប ដើម្បីចុះសន្ធិសញ្ញាទាំងឡាយអំពីការធ្វើ បត្យាប័នជាមួយនឹងរដ្ឋភាគីផ្សេងៗទៀតនៃអនុសញ្ញានេះ ដើម្បីអនុវត្តន៍មាត្រានេះបាន ។

៦- រដ្ឋភាគីទាំងឡាយ ដែលមិនបានដាក់ការធ្វើបត្យាប័នអាស្រ័យនឹងសន្ធិសញ្ញានេះទេ ត្រូវតែទទួលស្គាល់បទល្មើសទាំងឡាយរវាងគ្នានឹងគ្នា ដែលតាមការទទួលស្គាល់នេះ មាត្រានេះត្រូវអនុវត្តន៍ចំពោះលក្ខណៈជាបទល្មើស ដែលជនល្មើស អាចត្រូវធ្វើបត្យាប័ន។

៧- ការធ្វើបត្យាប័ន អាស្រ័យនឹងលក្ខខណ្ឌដែលចែងដោយច្បាប់ក្នុងស្រុករបស់រដ្ឋភាគីដែលត្រូវ បានស្នើសុំ ឬដោយសន្ធិសញ្ញាធ្វើបត្យាប័នដែលអាចអនុវត្តន៍បាន ដោយរាប់ទាំង ក្នុងនោះ លក្ខខណ្ឌទាំងឡាយដែលទាក់ទងនឹងតំរូវការនៃទណ្ឌកម្មអប្បបរិមាសំរាប់ការធ្វើបត្យាប័ន និងហេតុផលទាំងឡាយដែលរដ្ឋភាគីដែលត្រូវបានស្នើសុំនោះ អាចបដិសេធចំពោះការធ្វើបត្យាប័ននោះ ។

៨- រដ្ឋភាគីទាំងឡាយ លើកលែងតែច្បាប់ក្នុងស្រុករបស់ខ្លួន ត្រូវតែខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យបានរួសរាន់នូវនីតិវិធីធ្វើបត្យាប័ន និងធ្វើឱ្យងាយស្រួលនូវតំរូវការខាងភស្តុតាង ដែលទាក់ទងនឹងបទល្មើសណាដែលមាត្រានេះ ត្រូវអនុវត្តន៍ទៅលើនោះ ។

៩- លើកលែងតែបទបញ្ញត្តិទាំងឡាយនៃច្បាប់ក្នុងស្រុក និងសន្ធិសញ្ញាធ្វើបត្យាប័ន ដែលរដ្ឋភាគីបានចុះ រដ្ឋភាគីដែល ត្រូវបានស្នើសុំនោះ បន្ទាប់ពីពេញចិត្តថាកាលៈទេសៈទាំងឡាយពិតជាត្រឹមត្រូវ និងមានលក្ខណៈជាបន្ទាន់ ហើយនឹងតាមសំណើររបស់រដ្ឋភាគីដែលបានស្នើសុំ អាចឃុំឃាំងខ្លួនបុគ្គលម្នាក់ដែលការធ្វើបត្យាប័នរបស់បុគ្គលនោះ ត្រូវបានស្វះស្វែងរក ហើយដែលមានវត្តមាននៅក្នុងទឹកដីរបស់ខ្លួន ឬអាចចាត់វិធានការសមស្របទាំងឡាយ ដើម្បីធានាវត្តមានបុគ្គលនោះ នៅពេលនីតិវិធីធ្វើបត្យាប័ន ។

១០- រដ្ឋភាគីមួយ ដែលជនប្រព្រឹត្តិបទល្មើសដែលត្រូវបានចោទប្រកាន់ម្នាក់ ត្រូវបានរកឃើញនៅក្នុងទឹកដីរបស់ខ្លួន ប្រសិនបើខ្លួន មិនធ្វើបត្យាប័នបុគ្គលនោះចំពោះបទល្មើសមួយ ដែលមាត្រានេះ ត្រូវអនុវត្តន៍ទេ ដោយសារតែមានហេតុផលតែមួយគត់ថាបុគ្គលនោះ គឺជាអណិកជនម្នាក់របស់ខ្លួននោះ ត្រូវតែមានកាតព្វកិច្ចដាក់ជូនរឿងក្តីនេះ ដោយគ្មានការពន្យាពេលហួសហេតុ ទៅជូនអាជ្ញាធរមាន

សមត្ថកិច្ចរបស់រដ្ឋភាគីនោះ ដើម្បីធ្វើការចោទប្រកាន់។ អាជ្ញាធរមានសមត្ថកិច្ចទាំងនោះ ត្រូវតែធ្វើសេចក្តីសំរេចរបស់ខ្លួន និងចោទប្រកាន់ក្នុងលក្ខណៈដូចគ្នា ទៅនឹងករណីនៃបទល្មើសធ្ងន់ធ្ងរណាមួយផ្សេងទៀត នៅក្រោមច្បាប់ក្នុងស្រុករបស់រដ្ឋភាគីនោះផងដែរ ។ រដ្ឋភាគីផ្សេងៗទៀត ដែលពាក់ព័ន្ធ ត្រូវតែសហការជាមួយគ្នា ជាពិសេសនៅ លើទិដ្ឋភាពផ្នែកនីតិវិធី និងភស្តុតាងដើម្បីធានាឱ្យមានប្រសិទ្ធិភាពនៃការចោទប្រកាន់នេះ ។

១១- នៅពេលណាដែលរដ្ឋភាគីមួយ ដោយធ្វើទៅតាមច្បាប់ក្នុងស្រុករបស់ខ្លួន ត្រូវបានអនុញ្ញាតិអោយធ្វើបត្យាប័ន ឬ ប្រគល់អាណិកជនរបស់ខ្លួន តែថាបុគ្គលនេះ នឹងត្រូវបានបញ្ជូនត្រឡប់មកកាន់រដ្ឋភាគីនោះវិញ ដើម្បីទទួលទោស ដែលបានប្រកាសហើយ បន្ទាប់ពីការជំនុំជំរះរឿងក្តីនោះ ឬនីតិវិធីដែលចេញមកពីសំណើរធ្វើបត្យាប័ន ឬការប្រគល់ខ្លួនបុគ្គលនោះ និងថារដ្ឋភាគីនោះ និងរដ្ឋភាគីសុំការធ្វើបត្យាប័នបុគ្គលនោះ បានយល់ព្រមជាមួយគ្នាអំពីជំរើសនេះ ហើយនិងលក្ខខ័ណ្ឌផ្សេងៗទៀត ដែលរដ្ឋទាំងពីរនេះចាត់ទុកថាមានលក្ខណៈសមស្រប ការធ្វើបត្យាប័ន ឬការប្រគល់ខ្លួនដោយមានលក្ខខណ្ឌបែបនេះ ត្រូវមានលក្ខណៈគ្រប់គ្រាន់ក្នុងគោលបំណងអនុវត្ត កាតព្វកិច្ច ដែលមានចែងនៅក្នុងកថាខណ្ឌ ១០ នៃមាត្រានេះ ។

១២- ប្រសិនបើការធ្វើបត្យាប័ន ដែលត្រូវបានស្នើរសុំក្នុងគោលបំណងនៃការអនុវត្តនីទោសមួយ ត្រូវបានបដិសេធ ពីព្រោះបុគ្គល ដែលត្រូវបានស្នើរសុំធ្វើបត្យាប័ននោះ គឺជាអណិកជនរបស់រដ្ឋភាគីដែលត្រូវបានស្នើសុំ រដ្ឋភាគីដែលត្រូវបានស្នើសុំនោះ ប្រសិនបើច្បាប់ក្នុងស្រុករបស់ខ្លួន បានអនុញ្ញាត ហើយស្របតាមអាជ្ញាយុកាលនៃច្បាប់ និង តាមសំណើររបស់រដ្ឋស្នើរសុំ ត្រូវតែពិចារណាអំពីការអនុវត្តនីទោស ដែលស្ថិតនៅក្រោមច្បាប់ក្នុងស្រុករបស់ភាគី ដែលបានស្នើសុំនោះ ឬផ្នែកនៃទោស ដែលនៅសេសសល់នោះ ។

១៣- បុគ្គលណា ដែលជាកម្មវត្ថុនៃការចោទប្រកាន់ ចំពោះបទល្មើសមួយក្នុងចំនោមបទល្មើសទាំងឡាយ ដែលមាត្រានេះត្រូវគេ អនុវត្តនីនោះ ត្រូវតែទទួលបានការធានានូវការប្រព្រឹត្តចំពោះខ្លួនដោយត្រឹមត្រូវនៅគ្រប់ដំណាក់ កាលនៃនីតិវិធី ដោយរាប់ទាំងការទទួលបាននូវសិទ្ធិ និងការធានាទាំងឡាយ ដែលបានផ្តល់ ឱ្យដោយច្បាប់ក្នុងស្រុករបស់រដ្ឋភាគីនោះ នៅក្នុងទឹកដីដែលបុគ្គលនោះ មានវត្តមាន ។

១៤- គ្មានបទបញ្ញត្តិណាមួយនៅក្នុងអនុសញ្ញានេះ នឹងត្រូវបានបកស្រាយថាជាការដាក់កាតព្វកិច្ចមួយ ដើម្បីធ្វើបត្យាប័នទេ ប្រសិនបើរដ្ឋភាគីដែលត្រូវបានស្នើសុំនោះ មានហេតុផលយ៉ាងក្រាស់ក្រែលសំរាប់អោយគេជឿជាក់ថាសំណើរនោះ ត្រូវបានធ្វើឡើងសំរាប់គោលបំណងនៃការចោទប្រកាន់ ឬការ

ផ្តន្ទាទោសបុគ្គលម្នាក់ ដោយសារតែមូលហេតុនៃភេទ ពូជសាសន៍ សាសនា សញ្ជាតិ ដើមកំណើតជាជនជាតិភាគតិច ឬមតិ យោបល់នយោបាយរបស់បុគ្គលនោះទេ ឬអោយគេជឿថា តាមសំណើរនោះ នឹងបណ្តាលឱ្យមានព្យសនកម្មដល់បុគ្គលនោះ សំរាប់ហេតុផលណាមួយនៃហេតុផលទាំងឡាយនេះ ។

១៥- រដ្ឋភាគីទាំងឡាយ មិនអាចបដិសេធសំណើរសុំធ្វើបត្យាប័ន ដោយសារតែហេតុផល តែមួយគត់ថាបទល្មើសនោះ ត្រូវបានចាត់ទុកផងដែរថាពាក់ព័ន្ធជាមួយនឹងបញ្ហាសារពើពន្ធ ។

១៦- មុនពេលបដិសេធការធ្វើបត្យាប័ន រដ្ឋភាគីដែលត្រូវបានស្នើសុំ ត្រូវតែពិគ្រោះយោបល់ ប្រសិនបើមានជាមួយនឹងរដ្ឋភាគីដែលបានស្នើសុំ ដើម្បីផ្តល់ឱ្យភាគីស្នើរសុំនោះផ្តល់យោបល់របស់ខ្លួន និងផ្តល់ពត៌មានផ្សេងៗដើម្បីសំអាងទឡ្ហីករណ៍របស់ខ្លួន។

១៧- រដ្ឋភាគីទាំងឡាយ ត្រូវតែខិតខំស្វះស្វែងរកការចុះកិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងទ្វេភាគី និងពហុភាគីនានា ដើម្បីអនុវត្តន៍ ឬបង្កើនប្រសិទ្ធិភាពនៃការធ្វើបត្យាប័ន ។

## មាត្រា ១៧

### ការផ្ទេរបុគ្គល ដែលបានផ្តន្ទាទោស:

រដ្ឋភាគីទាំងឡាយ អាចពិចារណាអំពីការចុះកិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងទ្វេភាគី និងពហុភាគីនានាស្តីពីការផ្ទេរទៅកាន់ទឹកដីរបស់ខ្លួននូវបុគ្គលទាំងឡាយ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ ឬទោសទាំងឡាយនៃការដកហូតសេរីភាពចំពោះបទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ ដើម្បីអោយបុគ្គលទាំងនោះទទួលទោសដែលនៅសេសសល់ ។

## មាត្រា ១៨

### ជំនួយផ្នែកតុលាការទៅវិញទៅមក:

១- រដ្ឋភាគីទាំងឡាយ យល់ព្រមផ្តល់ឱ្យគ្នាទៅវិញទៅមកនូវវិធានការដ៏ទូលំទូលាយ ដែលអាចធ្វើទៅបាននៃជំនួយផ្នែកតុលាការ នៅក្នុងការស៊ើបអង្កេត ការចោទប្រកាន់ និងនីតិវិធីតុលាការដែលទាក់ទងជាមួយ នឹងបទល្មើស ដែលមានចែងនៅក្នុងអនុសញ្ញានេះ ដូចមានចែងនៅក្នុងមាត្រា ៣ យល់ព្រមឱ្យគ្នាទៅវិញទៅមកនូវជំនួយស្រដៀងគ្នានេះផងដែរ នៅពេលដែលរដ្ឋភាគីដែលបានស្នើសុំមានហេតុផលសម ស្របដើម្បីធ្វើអោយមានមន្ទិលសង្ស័យថា បទល្មើស ដែលបាននិយាយសំដៅនៅក្នុងមាត្រា ៣ កថាខណ្ឌទី ១ ចំនុច (ក) ឬចំនុច (ខ) មានចរិតលក្ខណៈឆ្លងដែន ដោយរាប់ទាំងនៅពេល

ជនរងគ្រោះ សាក្សី ផលិតផលអំពើឧក្រិដ្ឋកម្ម មធ្យោបាយ ឬធាតុផ្សំផ្សេងៗនៃភស្តុតាងនៃបទល្មើស បែបនេះ មានទីតាំងនៅក្នុងរដ្ឋភាគីដែល ត្រូវបានស្នើសុំ ហើយថាបទល្មើសនោះ មានការពាក់ព័ន្ធជាមួយនឹងក្រុមបណ្តាញឧក្រិដ្ឋជន ។

២- ជំនួយផ្នែកតុលាការ ត្រូវតែផ្តល់ឱ្យគ្នាទៅវិញទៅមកឱ្យបានពេលលេញតាមដែលអាច ធ្វើទៅបាន ដូចដែលច្បាប់ សន្ធិសញ្ញា កិច្ចព្រមព្រៀង និងការរៀបចំចាត់ចែងទាំងឡាយដែលសមរម្យរបស់រដ្ឋភាគីដែលត្រូវបានស្នើសុំ អនុញ្ញាតិនៅពេលស៊ើបអង្កេត ការចោទប្រកាន់ និង នីតិវិធីតុលាការ ដែលពាក់ព័ន្ធជាមួយនឹងបទល្មើសទាំងឡាយ ដែលនីតិបុគ្គលម្នាក់ អាចទទួលខុសត្រូវស្របតាម មាត្រា ១០ នៃអនុសញ្ញានេះ ។

៣- ជំនួយផ្នែកតុលាការទៅវិញទៅមក ដែលត្រូវតែផ្តល់ឱ្យគ្នាទៅវិញទៅមកស្របតាមមាត្រានេះ អាចត្រូវបានស្នើសុំសំរាប់គោលបំណងណាមួយក្នុងចំណោមគោលបំណងដូចខាងក្រោមនេះ:

(ក) ប្រមូលចម្លើយសាក្សី ឬ ចម្លើយកសិណ

(ខ) អោយដំណឹងកិច្ចតុលាការ

(គ) អនុវត្តន៏ការឆែកឆេរ និងការបង្ខាំងទុក ឬការរឹបអូសយក

(ឃ) ត្រួតពិនិត្យមើលវត្ថុ និងទីកន្លែង

(ង) ផ្តល់ពត៌មាន វត្ថុតាង និងការវាយតំលៃរបស់អ្នកជំនាញការ

(ច) ផ្តល់ច្បាប់ដើម ឬច្បាប់ចំលងត្រឹមត្រូវនៃឯកសារ និងរបាយការណ៍ដែលពាក់ព័ន្ធ ដោយរាប់ទាំងរបាយការណ៍រដ្ឋបាល របាយការណ៍របស់ធនាគារ របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍ពាណិជ្ជកម្ម និង របាយការណ៍សហគ្រាស

(ឆ) បង្ហាញអត្តសញ្ញាណ ឬ បង្ហាញទីតាំងផលិតផលអំពើឧក្រិដ្ឋកម្ម ទ្រព្យសម្បត្តិ ឧបករណ៍ ឬវត្ថុអ្វីៗផ្សេងៗទៀត ដើម្បីប្រមូលធាតុផ្សំនៃភស្តុតាង

(ជ) សំរបសំរួលដល់ការបង្ហាញមុខដោយស្ម័គ្រចិត្តរបស់បុគ្គលនោះ នៅក្នុងរដ្ឋភាគីដែលបានស្នើសុំ

(ឈ) ផ្តល់ជំនួយបែបណាមួយផ្សេងទៀត ដែលមិនមានលក្ខណៈផ្ទុយទៅនឹងច្បាប់ក្នុងស្រុករបស់រដ្ឋភាគី ដែលត្រូវបានស្នើសុំនោះ ។

៤- ដោយមិនបង្ករព្យាសនកម្មដល់ច្បាប់ក្នុងស្រុកនោះ អាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋភាគីមួយ ដោយមិនចាំបាច់មានការស្នើសុំជាមុន អាចបញ្ជូនពត៌មានដែលទាក់ទងជាមួយនឹងរឿងក្តីព្រហ្មទណ្ឌទៅកាន់អាជ្ញាធរ មានសមត្ថកិច្ចនៅក្នុងរដ្ឋភាគីមួយផ្សេងទៀត ដែលគេមានជំនឿថាពត៌មានបែបនេះអាចនឹងជួយដល់ អាជ្ញាធរនោះនៅក្នុងការចាប់ផ្តើម ឬការបញ្ចប់ការស៊ើបអង្កេតនិងការចោទប្រកាន់ព្រហ្មទណ្ឌ ឬ អាចនឹងនាំអោយរដ្ឋភាគីខាងក្រោយនេះ ធ្វើសំណើរមួយអោយស្របតាមអនុសញ្ញានេះ ។

៥- ការបញ្ជូនពត៌មានស្របតាមកថាខណ្ឌទី ៤ នៃមាត្រានេះ ត្រូវតែធ្វើឡើងដោយពុំអោយមានព្យសនកម្ម និង ការចោទប្រកាន់ព្រហ្មទណ្ឌនៅក្នុងរដ្ឋ ដែលអាជ្ញាធរមានសមត្ថកិច្ច ផ្តល់ពត៌មាននោះ។ អាជ្ញាធរមានសមត្ថកិច្ច ដែលទទួលពត៌មាននោះ ត្រូវតែអនុវត្តន៏តាមសំណើរមួយ ដែលថាពត៌មានដែលបានលើកឡើងនោះ ត្រូវមានលក្ខណៈសំងាត់ សូម្បីតែក្នុងរយៈពេលបណ្តោះអាសន្ន ក៏ដោយ ឬត្រូវមានការរឹតបន្តឹងលើការប្រើប្រាស់ពត៌មាននោះ ។ តែទោះជាយ៉ាងណាក៏ដោយ ការអនុវត្តន៏តាមនេះ មិនត្រូវរារាំងដល់រដ្ឋភាគីដែលបានទទួលពត៌មាននោះពីការលាតត្រដាងនៅក្នុងនីតិវិធីតុលាការ ដែលធ្វើឱ្យបុគ្គលជាប់ចោទម្នាក់ដោះបន្ទុកឡើយ ។ នៅក្នុងករណីមួយបែបនេះ រដ្ឋភាគី ដែលបានទទួលពត៌មាននោះ ត្រូវតែជូនដំណឹងទៅរដ្ឋភាគីដែលបានបញ្ជូនពត៌មាននោះ ឱ្យមុនពេលមានការលាតត្រដាងនោះ ហើយប្រសិនបើមានការស្នើសុំ ត្រូវតែពិគ្រោះយោបល់ជាមួយនឹងរដ្ឋភាគីដែលបានបញ្ជូនពត៌មាននោះសិន ។ ប្រសិនបើស្ថិតក្នុងករណីលើកលែងមួយ ការជូនដំណឹងជាមុនមិនអាចធ្វើទៅបានទេ រដ្ឋភាគីដែលបានទទួលពត៌មាននោះ ត្រូវតែជូនដំណឹងទៅរដ្ឋភាគីដែលបានបញ្ជូនពត៌មានអំពីការលាតត្រដាងនោះ ដោយគ្មានការពន្យាពេលឡើយ ។

៦- បទបញ្ញត្តិទាំងឡាយនៅក្នុងមាត្រានេះ មិនត្រូវមានផលប៉ះពាល់ទៅលើកាតព្វកិច្ចនៅក្រោមសន្ធិសញ្ញាទ្វេភាគី ឬពហុភាគីណាមួយផ្សេងទៀត ដែលចែង ឬនឹងត្រូវចែងអំពីជំនួយផ្នែកយុត្តាធិការទៅវិញទៅមក ទាំងមូល ឬជាផ្នែកឡើយ ។

៧- ចាប់ពីកថាខណ្ឌទី ៩ ដល់កថាខណ្ឌទី ២៩ នៃមាត្រានេះ ត្រូវអនុវត្តន៏ចំពោះសំណើរទាំងឡាយ ដែលបានធ្វើឡើងស្របតាមមាត្រានេះ ប្រសិនបើរដ្ឋភាគីទាំងឡាយដែលមានបញ្ហានោះ មិនបានជាប់ចំណងគ្នា

ដោយសន្ធិសញ្ញានៃជំនួយផ្នែកច្បាប់ទៅវិញទៅមកមួយទេ ។ ប្រសិនបើរដ្ឋភាគីទាំងនោះមានចំណងជាមួយនឹងគ្នាដោយ សន្ធិសញ្ញាមួយបែបនេះ បទបញ្ញត្តិទាក់ទងគ្នានៃសន្ធិសញ្ញានោះត្រូវតែបានអនុវត្តន៍ ដរាបណាតែរដ្ឋភាគីទាំងនោះ បានយល់ព្រមលើការអនុវត្តន៍ចាប់ពីកថាខណ្ឌទី ៩ ដល់កថាខណ្ឌទី ២៩ នៃមាត្រានេះជាជំនួស វិញតែប៉ុណ្ណោះ ។ រដ្ឋភាគីទាំងឡាយត្រូវបានលើកទឹកចិត្តយ៉ាងខ្លាំងក្លាឱ្យអនុវត្តន៍កថាខណ្ឌទាំងនេះ ប្រសិនបើពួកគេ សំរបសំរួលលើកិច្ចសហប្រតិបត្តិការនេះ ។

៨- រដ្ឋភាគីទាំងឡាយ មិនត្រូវប្រកែកមិនយល់ព្រមផ្តល់នូវជំនួយផ្នែកតុលាការទៅវិញទៅមកស្របតាមមាត្រា នេះ ដោយសារតែមានហេតុផលនៃការសំងាត់ផ្នែកធនាគារឡើយ ។

៩- រដ្ឋភាគីទាំងឡាយ អាចប្រកែកមិនយល់ព្រមផ្តល់នូវជំនួយផ្នែកតុលាការទៅវិញទៅមកបានស្របតាមមា ត្រានេះ ដោយសារតែមានហេតុផលនៃការមិនមានការចោទប្រកាន់ទ្វេដង ។ តែទោះជាយ៉ាងណាក៏ដោយ រដ្ឋភាគីដែលត្រូវបានស្នើសុំ នៅពេលដែលខ្លួនយល់ថាជាការសមស្រប អាចផ្តល់ជំនួយទៅតាម ការសំរេចចិត្តដោយឆន្ទានុសិទ្ធិរបស់ខ្លួន ដោយគ្មានគិតទៅដល់ថាការប្រព្រឹត្តនេះគឺជា បទល្មើសមួយ រឺ អត់ នៅក្រោមច្បាប់ក្នុងស្រុករបស់រដ្ឋភាគីដែលត្រូវបានស្នើសុំនោះ ។

១០- បុគ្គលគ្រប់រូប ដែលកំពុងត្រូវបានឃុំឃាំងខ្លួន ឬរងទោស នៅក្នុងទឹកដីនៃរដ្ឋភាគីមួយដែលវត្តមានរបសបុគ្គលនោះ នៅក្នុងរដ្ឋភាគីមួយផ្សេងទៀត ត្រូវបានស្នើសុំសំរាប់គោលបំណងនៃការបង្ហាញអត្តសញ្ញាណ ចំលើយកសិណសាក្សី ឬផ្តល់ជំនួយនៅក្នុងការទទួលបាននូវភស្តុតាងសំរាប់ការស៊ើបអង្កេត ការចោទប្រកាន់ ឬនីតិវិធីតុលាការ ដែលពាក់ព័ន្ធជាមួយនឹងបទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ អាចជាកម្មវត្ថុបញ្ជូនខ្លួនទៅរដ្ឋស្នើរសុំ ប្រសិនបើលក្ខខណ្ឌទាំងឡាយ ដូចខាងក្រោមនេះ ត្រូវបានបំពេញ:

(ក) បុគ្គលនោះ បានផ្តល់ការយល់ព្រមដោយខ្លួនឯង និង ដោយដឹងពីហេតុផលច្បាស់លាស់

(ខ) អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីទាំងពីរ បានយល់ព្រម ដែលជាកម្មវត្ថុនៃលក្ខខណ្ឌបែបនេះ នៅពេលដែលរដ្ឋភាគីទាំងនោះ អាចយល់ឃើញថាជាការសមស្រប ។

១១- សំរាប់គោលបំណងរបស់កថាខណ្ឌទី ១០ នៃមាត្រានេះ:

(ក) រដ្ឋភាគី ដែលបុគ្គលនោះ ត្រូវបានបញ្ជូនទៅ មានសិទ្ធិអំណាច និងកាតព្វកិច្ច ដើម្បីឃុំឃាំងបុគ្គលនោះ លើកលែងតែមានការស្នើសុំ ឬមាន ការអនុញ្ញាតផ្សេងពីនេះ ពីរដ្ឋភាគី ដែលបុគ្គលនោះ ត្រូវបានបញ្ជូនខ្លួន

(ខ) រដ្ឋភាគី ដែលបុគ្គលនោះ ត្រូវបានបញ្ជូនទៅ ដោយគ្មានការពន្យាពេល ត្រូវតែអនុវត្តន៍កាតព្វកិច្ចរបស់ខ្លួន ដើម្បីបញ្ជូនបុគ្គលនោះត្រឡប់ទៅឱ្យរដ្ឋភាគីដែលបុគ្គលនោះ ត្រូវបានបញ្ជូនខ្លួនចេញមកវិញដើម្បីឃុំឃាំងខ្លួន ដូចបានព្រមព្រៀងគ្នាពីមុន ឬបានព្រមព្រៀងគ្នាដោយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីទាំងពីរ

(គ) រដ្ឋភាគី ដែលបុគ្គលនោះ ត្រូវបានបញ្ជូនទៅ មិនត្រូវតំរូវឱ្យរដ្ឋភាគី ដែលបុគ្គលនោះ ត្រូវបានបញ្ជូនខ្លួនចេញមកវិញនោះ ត្រូវធ្វើនីតិវិធីធ្វើបត្យាប័នសំរាប់ការបញ្ជូនខ្លួនបុគ្គលនោះ ត្រឡប់ទៅវិញឡើយ

(ឃ) បុគ្គលដែលត្រូវបានបញ្ជូនខ្លួនទៅនោះ ត្រូវតែទទួលបានការរាប់បញ្ចូលទោសសំរាប់រយៈពេល ដែលបុគ្គលនោះត្រូវបានឃុំឃាំងនៅក្នុងរដ្ឋ ដែលបុគ្គលនោះ ត្រូវបានបញ្ជូនខ្លួន ចំពោះរដ្ឋភាគី ដែល បុគ្គលនោះ ត្រូវបានបញ្ជូនចេញមកវិញនោះ ។

១២- ដរាបណារដ្ឋភាគី ដែលបុគ្គលម្នាក់ នឹងត្រូវបានបញ្ជូនខ្លួនចេញមកវិញ ស្របតាមកថាខណ្ឌទី ១០ និងកថាខណ្ឌទី ១១ នៃមាត្រានេះ បានយល់ព្រម បុគ្គលនោះ មិនថាសញ្ជាតិរបស់ខ្លួនជាអ្វីនោះទេ មិនត្រូវបានចោទប្រកាន់ទោស ឃុំឃាំងខ្លួន ដាក់ទណ្ឌកម្ម ឬជាកម្មវត្ថុនៃការរឹតបន្តឹងណាមួយផ្សេងទៀតដល់សេរីភាពចលនានៅក្នុងទឹកដីនៃរដ្ឋដែលបុគ្គលនោះ ត្រូវបានបញ្ជូនខ្លួនទៅចំពោះអំពើ ការខកខាន ឬការផ្តន្ទាទោស មុនពេលចេញដំណើររបស់ខ្លួនពីទឹកដីនៃរដ្ឋ ដែលខ្លួនត្រូវបានបញ្ជូនចេញមកវិញនោះទេ។

១៣- រដ្ឋភាគីនិមួយៗ ត្រូវតែចាត់តាំងអាជ្ញាធរកណ្តាលមួយ ដែលមានការទទួលខុសត្រូវ និងអំណាច ដើម្បីទទួលសំណើរទាំងឡាយសំរាប់ជំនួយផ្នែកតុលាការទៅវិញទៅមកនេះ និង ដើម្បីអនុវត្តន៍សំណើរទាំងនោះ ឬបញ្ជូនសំណើរទាំងនោះទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចដើម្បីអនុវត្តន៍ ។ រដ្ឋភាគីមួយ ដែលមានតំបន់ ឬដែនដីពិសេសមួយ ដែលមានប្រព័ន្ធជំនួយផ្នែកតុលាការទៅវិញទៅមក ដាច់ដោយឡែកមួយនោះ អាចចាត់តាំងអាជ្ញាធរកណ្តាលផ្សេងពីនេះ ដែលត្រូវមានមុខនាទីដូចគ្នានេះ ផងដែរទៅនឹងតំបន់ ឬទឹកដីនោះ ។ អាជ្ញាធរកណ្តាលទាំងនេះ ត្រូវតែធានានៃការអនុវត្តន៍

និងការបញ្ជូនអោយបានលឿន និង ដោយត្រឹមត្រូវចំពោះសំណើរ ដែលបានទទួលទាំងនោះ ។ នៅពេលដែលអាជ្ញាធរកណ្តាល បញ្ជូនសំណើរ នោះទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចមួយទៀត ដើម្បីអនុវត្តន៍ អាជ្ញាធរកណ្តាលនេះ ត្រូវតែលើកទឹកចិត្ត ឱ្យមានការអនុវត្តន៍សំណើរនោះអោយបានលឿន ដោយអាជ្ញាធរមានសមត្ថកិច្ចនោះ ។ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវតែបានជូនដំណឹងអំពីអាជ្ញាធរកណ្តាល ដែលបានចាត់តាំងឡើងនោះសំរាប់គោលបំណងនេះ នៅពេលដែលរដ្ឋភាគីនិមួយៗ ដាក់ជូនមធ្យោបាយរបស់ខ្លួនសំរាប់ការផ្តល់សច្ចាប័ន ព្រមទទួលយក អនុម័តទទួលយក ឬការទទួលយកអនុសញ្ញានេះជាផ្លូវការ ។ សំណើរសំរាប់ជំនួយផ្នែកតុលាការទៅវិញទៅមក និងការប្រាស្រ័យទាក់ទងណាមួយ ដែលទាក់ទងទៅនឹងបញ្ហានោះ ត្រូវតែបញ្ជូនទៅ ឱ្យអាជ្ញាធរកណ្តាល ដែលបានចាត់តាំងដោយរដ្ឋភាគីទាំងនោះ ។ បញ្ញត្តិនេះ ត្រូវតែមិនមានសេចក្តី ដោយមិនបង្ករអោយមានព្យសនកម្ម ចំពោះនីតិរបស់រដ្ឋភាគីមួយ ថាសំណើរ និងការប្រាស្រ័យទាក់ទងបែបនោះ ត្រូវតែលើកឡើងមកខ្លួនតាមរយៈផ្លូវការទូត ហើយក្នុងកាលៈទេសៈជាបន្ទាន់ ដែលរដ្ឋភាគីទាំងនោះ បានយល់ ព្រមតាមរយៈអង្គការប៉ូលីសព្រហ្មទណ្ឌអន្តរជាតិ ប្រសិនបើអាចធ្វើទៅបាន ។

១៤- សំណើរ ត្រូវតែធ្វើឡើងជាលាយលក្ខអក្សរ ឬបើអាចធ្វើទៅបាន តាមមធ្យោបាយណាមួយ ដែលអាចធ្វើជាឯកសារជាលាយលក្ខអក្សរមួយបាន ជាភាសាមួយ ដែលរដ្ឋភាគីដែលត្រូវបានស្នើសុំ អាចទទួលយកបាន នៅក្រោមលក្ខខណ្ឌដែលអនុញ្ញាតឱ្យរដ្ឋភាគីនោះ បង្កើតការបញ្ជាក់យថាភាព ។ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវតែបានជូនដំណឹងអំពីភាសានោះ ឬភាសាទាំងឡាយ ដែលអាចទទួលយកបានសំរាប់រដ្ឋភាគីនិមួយៗ នៅពេលដែលខ្លួនដាក់ជូនមធ្យោបាយរបស់ខ្លួនសំរាប់ការផ្តល់សច្ចាប័ន ព្រមទទួលយក អនុម័តទទួលយក ឬការទទួលយកអនុសញ្ញានេះជាផ្លូវការ ។ នៅក្នុងកាលៈទេសៈជាបន្ទាន់ និងដែលបានយល់ព្រមដោយរដ្ឋភាគីទាំងនោះ សំណើរទាំងឡាយ អាចត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ប៉ុន្តែត្រូវមានការបញ្ជាក់ជាលាយលក្ខអក្សរ នៅពេលបន្ទាប់មកទៀត ។

១៥- សំណើរមួយ សំរាប់ជំនួយផ្នែកតុលាការទៅវិញទៅមក ត្រូវមានៈ

(ក) អត្តសញ្ញាណរបស់អាជ្ញាធរ ដែលបានធ្វើសំណើរនោះ

(ខ) កម្មវត្ថុ និងចរិតលក្ខណៈនៃការស៊ើបអង្កេត ការចោទប្រកាន់ ឬនីតិវិធីតុលាការ ដែលសំណើរនោះមានការពាក់ព័ន្ធ ព្រមទាំងឈ្មោះ និងមុខនាទីរបស់អាជ្ញាធរ ដែលអនុវត្តនីការស៊ើបអង្កេត ការចោទប្រកាន់ ឬនីតិវិធីតុលាការនោះ

(គ) សេចក្តីសង្ខេបមួយអំពីហេតុការណ៍ដែលពាក់ព័ន្ធ លើកលែងតែសំណើរធ្វើឡើង សំរាប់គោលបំណងនៃប្រវេទន៍ កិច្ចតុលាការតែប៉ុណ្ណោះ

(ឃ) សេចក្តីពិពណ៌នាមួយអំពីជំនួយ ដែលត្រូវបានស្វះស្វែងរកនោះ និងសេចក្តីពិស្តារអំពីនីតិវិធីជាពិសេសណាមួយ ដែលរដ្ឋភាគីដែលបានស្នើសុំនោះ ប្រាថ្នាចង់ឱ្យមានការអនុវត្តន៍តាម

(ង) ប្រសិនបើអាចធ្វើទៅបាន គឺអត្តសញ្ញាណ អាស័យដ្ឋាន និងសញ្ជាតិរបស់បុគ្គលណាមួយដែលពាក់ព័ន្ធ និង

(ច) គោលបំណង ដែលភស្តុតាង ពត៌មាន ឬសកម្មភាព ត្រូវបានស្វះស្វែងរក ។

១៦- រដ្ឋភាគីដែលត្រូវបានស្នើសុំនោះ អាចស្នើសុំពត៌មានជាបន្ថែមទៀត នៅពេលដែល ខ្លួនយល់ឃើញថាមានការចាំបាច់ សំរាប់ការអនុវត្តន៍សំណើរនោះស្របតាមច្បាប់ក្នុងស្រុករបស់ខ្លួន ឬនៅពេលដែលខ្លួនយល់ថា អាចធ្វើអោយងាយស្រួលដល់ការអនុវត្តន៍នេះ ។

១៧- សំណើរមួយ ត្រូវតែបានអនុវត្តន៍អោយស្របតាមច្បាប់ក្នុងស្រុករបស់រដ្ឋភាគីដែលត្រូវបានស្នើសុំនោះ ហើយប្រសិនបើ មិនមានលក្ខណៈផ្ទុយទៅនឹងច្បាប់ក្នុងស្រុករបស់រដ្ឋភាគីដែលត្រូវបានស្នើសុំនោះ និងប្រសិនបើអាចធ្វើទៅបាន ត្រូវអនុវត្តអោយស្របតាមនីតិវិធី ដែលបានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងសំណើរនោះ ។

១៨- តាមដែលអាចធ្វើទៅបាន និងស្របតាមគោលការណ៍ជាមូលដ្ឋាននៃច្បាប់ក្នុងស្រុក នៅពេលដែលបុគ្គលម្នាក់ ស្ថិតនៅក្នុងទឹកដីនៃរដ្ឋភាគីមួយ ហើយត្រូវធ្វើជាសាក្សីម្នាក់ ឬធ្វើជាអ្នកជំនាញការម្នាក់នៅក្នុងសវនាការមួយ ដែលធ្វើឡើងដោយអាជ្ញាធរតុលាការនៃរដ្ឋភាគីមួយផ្សេងទៀតនោះ រដ្ឋភាគីទី ១ ដោយមានការស្នើសុំពីរដ្ឋភាគីផ្សេងទៀតនោះ អាចអនុញ្ញាតឱ្យសវនាការនោះប្រព្រឹត្តធ្វើឡើងដោយសន្និសិទបញ្ចាំងវីដេអូ ប្រសិនបើវាមានលក្ខណៈមិនអាចធ្វើបាន ឬគួរឱ្យចង់បានថា បុគ្គលនោះ បង្ហាញមុខដោយផ្ទាល់នៅក្នុងទឹកដីនៃរដ្ឋភាគីដែលបានស្នើសុំនោះ ។ រដ្ឋភាគីទាំងឡាយ

អាចយល់ស្របគ្នាថាសវនាការនោះ ត្រូវធ្វើឡើងដោយអាជ្ញាធរតុលាការមួយរបស់រដ្ឋភាគី ដែលបានស្នើសុំនោះ និងត្រូវបានចូលរួមដោយអាជ្ញាធរតុលាការមួយរបស់រដ្ឋភាគីដែលត្រូវបានស្នើសុំ ។

១៩- រដ្ឋភាគីដែលបានស្នើសុំ មិនត្រូវបញ្ជូន ឬប្រើប្រាស់ពត៌មាន ឬធាតុផ្សំនៃភស្តុតាង ដែលបានផ្តល់ឱ្យដោយរដ្ឋភាគី ដែលត្រូវបានស្នើសុំសំរាប់ការស៊ើបអង្កេត ការចោទប្រកាន់ ឬនីតិវិធីតុលាការទេ លើកលែងតែពត៌មាន ដែលបានគូសបញ្ជាក់នៅក្នុងសំណើរនោះ ដោយគ្មានការយល់ព្រមជាបឋមពីរដ្ឋភាគី ដែលត្រូវបានស្នើសុំនោះទេ ។ គ្មានបទបញ្ញត្តិណាមួយនៅក្នុងកថាខណ្ឌនេះ នឹងត្រូវបានរារាំងរដ្ឋភាគី ដែលបានស្នើសុំ ពីការលាតត្រដាងនៅក្នុងនីតិវិធីនូវពត៌មាន ឬធាតុផ្សំនៃភស្តុតាងរបស់ខ្លួន ដែលមានលក្ខណៈធ្វើ ឱ្យបុគ្គលជាប់ ចោទម្នាក់សំរាលបន្ទុកឡើយ ។ នៅក្នុងករណីនេះ រដ្ឋភាគីដែលបានស្នើសុំ ត្រូវតែជូន ដំណឹងទៅរដ្ឋភាគីដែលត្រូវបានស្នើសុំ មុនពេលមានការលាតត្រដាងនោះ ហើយប្រសិនបើមានការស្នើសុំ ត្រូវតែពិគ្រោះយោបល់ជាមួយនឹងរដ្ឋភាគីដែលត្រូវបានស្នើសុំនោះ។ ប្រសិនបើនៅក្នុងករណីលើកលែង មួយ ការជូនដំណឹងជាមុន មិនអាចធ្វើទៅបាន រដ្ឋភាគីដែលបានស្នើសុំនោះ ត្រូវតែផ្តល់ពត៌មានទៅអោយ រដ្ឋភាគីដែលត្រូវបានស្នើសុំអំពីការលាតត្រដាងនោះ ដោយគ្មានការពន្យាពេលឡើយ ។

២០- រដ្ឋភាគីដែលបានស្នើសុំ អាចតំរូវថា រដ្ឋភាគីដែលត្រូវបានស្នើសុំនោះ ត្រូវរក្សាការសំងាត់អំពីសំណើរ និងខ្លឹមសារនៃសំណើរនោះ លើកលែងតែមានការចាំបាច់ដើម្បីអនុវត្តន៍សំណើរនោះតែប៉ុណ្ណោះ ។ ប្រសិនបើរដ្ឋភាគីដែលត្រូវបានស្នើសុំនោះ មិនអាចអនុវត្តន៍តាមតំរូវការនៃការរក្សាការសំងាត់នេះទេ ខ្លួនត្រូវតែជំរាបជូនពត៌មានទៅរដ្ឋភាគីដែលបានស្នើសុំនោះ ភ្លាមជាបន្ទាន់ ។

២១- ជំនួយផ្នែកតុលាការទៅវិញទៅមក អាចត្រូវបានបដិសេធៈ

(ក) ប្រសិនបើសំណើរនោះ មិនត្រូវបានធ្វើឡើងស្របតាមបទបញ្ញត្តិទាំងឡាយនៃមាត្រានេះទេនោះ

(ខ) ប្រសិនបើរដ្ឋភាគីដែលត្រូវបានស្នើសុំនោះ ពិចារណាថាការអនុវត្តន៍សំណើរនោះនឹងធ្វើអោយប៉ះពាល់ដល់អធិបតេយ្យភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ឬផលប្រយោជន៍សំខាន់ៗផ្សេងៗទៀតរបស់ខ្លួន

(គ) ប្រសិនបើអាជ្ញាធរនៃរដ្ឋភាគីដែលត្រូវបានស្នើសុំ ត្រូវបានហាមប្រាមដោយច្បាប់ក្នុងស្រុករបស់ខ្លួន ពីការចាត់វិធានការ ដែលបានស្នើសុំ ប្រសិនបើវាជាបទល្មើសដូចគ្នានេះ ដែលបទល្មើសនោះ

ជាកម្មវត្ថុនៃការស៊ើបអង្កេត ការចោទប្រកាន់ ឬនីតិវិធីតុលាការ នៅក្រោមក្របខ័ណ្ឌនៃដែនសមត្ថកិច្ចរបស់ខ្លួនផ្ទាល់

(ឃ) ប្រសិនបើវាមានលក្ខណៈផ្ទុយទៅនឹងប្រព័ន្ធគតិយុត្តិរបស់រដ្ឋភាគីដែលត្រូវបានស្នើសុំ ដែលទាក់ទងជាមួយនឹងជំនួយផ្នែកតុលាការទៅវិញទៅមក សំរាប់សំណើរ ដែលត្រូវបានស្នើសុំនោះ ។

២២- រដ្ឋភាគីទាំងឡាយ មិនអាចបដិសេធចំពោះសំណើរមួយសំរាប់ជំនួយផ្នែកតុលាការទៅវិញទៅមក ដោយសារមានហេតុផលតែមួយគត់ ដែលថាបទល្មើសនោះ ត្រូវបានចាត់ទុកថាមានការពាក់ព័ន្ធជាមួយនឹងបញ្ហាសារពើពន្ធ ។

២៣- ហេតុផលទាំងឡាយ ត្រូវតែផ្តល់ជូនសំរាប់ការបដិសេធណាមួយ ចំពោះជំនួយផ្នែកតុលាការទៅវិញទៅមក ។

២៤- រដ្ឋភាគីដែលត្រូវបានស្នើសុំ ត្រូវតែអនុវត្តនីសំណើរសំរាប់ជំនួយផ្នែកតុលាការទៅវិញទៅមកនោះឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ហើយត្រូវទទួលខុសត្រូវឱ្យបានពេញលេញតាមដែលអាចធ្វើទៅបាន ចំពោះរយៈពេលកំណត់ ដែលបានស្នើឡើងដោយរដ្ឋភាគីដែលបានស្នើសុំនោះ និងសំរាប់ហេតុផលណាដែលបានផ្តល់ជូននៅក្នុងសំណើរនោះ ។ រដ្ឋភាគីដែលត្រូវបានស្នើសុំ ត្រូវតែឆ្លើយតបទៅនឹងសំណើរទាំងឡាយ ដែលមានលក្ខណៈសមស្របពីរដ្ឋភាគីដែលបានស្នើសុំ អំពីដំណើរការទៅមុខនៃការអនុវត្តនីសំណើរនោះ ។ នៅពេលដែលជំនួយទៅវិញទៅមក ដែលបានស្នើសុំ លែងចាំបាច់តទៅទៀត រដ្ឋភាគីដែលបានស្នើសុំ ត្រូវតែជូនដំណឹងភ្លាមជាបន្ទាន់ទៅរដ្ឋភាគីដែលត្រូវបានស្នើសុំ ។

២៥- ជំនួយផ្នែកតុលាការទៅវិញទៅមក អាចត្រូវបានលើកពេលទៅវិញដោយរដ្ឋភាគីដែលត្រូវបានស្នើសុំ ដោយសារ មានហេតុផលថា ជំនួយនោះបង្កើតជាឧបសគ្គដល់ការស៊ើបអង្កេត ការចោទប្រកាន់ ឬនីតិវិធីតុលាការ ដែលកំពុងតែដំណើរការ ។

២៦- មុនពេលបដិសេធសំណើរមួយ ដែលស្របតាមកថាខណ្ឌទី ២១ នៃមាត្រានេះ ឬមុនពេលលើកពេលអនុវត្តនីរបស់ខ្លួន ដែលស្របតាមកថាខណ្ឌទី ២៥ នៃមាត្រានេះ រដ្ឋភាគីដែលត្រូវបានស្នើសុំ ត្រូវតែសិក្សារជាមួយនឹងរដ្ឋភាគីដែលបានស្នើសុំនោះ នូវលទ្ធភាពយល់ព្រមផ្តល់ជំនួយអោយគ្នាទៅវិញទៅមកក្រោមលក្ខខ័ណ្ឌដែលខ្លួនយល់ឃើញថាមានការចាំបាច់ ។ ប្រសិនបើរដ្ឋភាគីដែលបានស្នើសុំនោះទទួលយកជំនួយក្រោមលក្ខខណ្ឌទាំងនោះ ខ្លួនត្រូវ តែអនុវត្តនីតាមលក្ខខណ្ឌទាំងនោះ ។

២៧- ដោយមិនបង្កើតព្យសនកម្មដល់ការអនុវត្តន៏កថាខណ្ឌទី ១២ នៃមាត្រានេះ សាក្សីម្នាក់ អ្នកជំនាញការម្នាក់ ឬបុគ្គលម្នាក់ តាមសំណើររបស់រដ្ឋភាគីដែលបានស្នើសុំ ដែលបានយល់ព្រមចូលខ្លួននៅក្នុងនីតិវិធីមួយ ឬជួយសហការក្នុងការស៊ើបអង្កេត ការចោទប្រកាន់ ឬនីតិវិធីតុលាការមួយនៅក្នុងទឹកដីរបស់រដ្ឋភាគីដែលបានស្នើសុំនោះ មិនត្រូវបានចោទប្រកាន់ទោស ឃុំឃាំងខ្លួន ផ្តន្ទាទោស ឬជាកម្មវត្ថុនៃការរឹតត្បិតផ្សេងៗទៀតណាមួយចំពោះសេរីភាពផ្ទាល់ខ្លួននៅក្នុងទឹកដីនោះឡើយ ទាក់ទងជាមួយនឹងអំពើ ការខកខាន ឬការផ្តន្ទាទោស មុនពេលចេញដំណើររបស់ខ្លួនពីទឹកដីនៃរដ្ឋភាគីដែលត្រូវបានស្នើសុំនោះទេ ។ អភ័យឯកសិទ្ធិនេះ ត្រូវតែបញ្ឈប់ទៅវិញនៅ ពេលដែលសាក្សី អ្នកជំនាញការ ឬបុគ្គលនោះ មានលទ្ធភាពដើម្បីចាកចេញពីទឹកដីរដ្ឋ ដែលស្នើសុំ ក្នុងរយៈពេល ១៥ ថ្ងៃជាប់ៗគ្នា ឬក្នុងរយៈពេលណាមួយ ដែលបានយល់ព្រមដោយរដ្ឋភាគីទាំងនោះ ចាប់ពីថ្ងៃដែលរដ្ឋភាគីទាំងនោះ ត្រូវបានជូនដំណឹងជាផ្លូវការថាវត្តមានរបស់បុគ្គលនោះ លែងត្រូវការតទៅទៀតដោយអាជ្ញាធរតុលាការ នោះហើយ ប៉ុន្តែយ៉ាងណាក៏ដោយ ពួកគេ បានស្ថិតនៅក្នុងទឹកដីនៃរដ្ឋភាគីដែលបានស្នើសុំនោះ ដោយស្ម័គ្រចិត្ត ឬបានចាកចេញពីទឹកដីនោះហើយបានវិលត្រឡប់ទៅវិញដោយឆន្ទៈដោយសេរីរបស់ខ្លួនផ្ទាល់ ។

២៨- ការចំណាយជាធម្មតានៃការអនុវត្តន៏សំណើរមួយ ត្រូវតែជាបន្ទុករបស់រដ្ឋភាគីដែលត្រូវបានស្នើសុំនោះ លើកលែងតែមានការយល់ព្រមផ្សេងពីនេះពីរដ្ឋភាគីដែលពាក់ព័ន្ធទាំងអស់នោះ ។ ប្រសិនបើការចំណាយមានលក្ខណៈមួយក្នុងចំនួនដ៏ក្រាស់ក្រែល ឬមិនធម្មតា ដែលត្រូវតែ ឬគួរឱ្យមានចំណាយជាចាំបាច់ពេលក្រោយមកទៀត ដើម្បីបំពេញសំណើរនោះ រដ្ឋភាគីទាំងអស់នោះ ត្រូវតែពិគ្រោះយោបល់គ្នាដើម្បីកំណត់លក្ខខណ្ឌ ដែលតាមលក្ខខណ្ឌនោះ សំណើរនោះ នឹងត្រូវបានអនុវត្តន៏ ក៏ដូចជារបៀបរបបទទួលបន្ទុកការចំណាយនោះ ផងដែរ ។

២៩- រដ្ឋភាគីដែលត្រូវបានស្នើសុំៈ

(ក) ត្រូវតែផ្តល់ទៅឱ្យរដ្ឋភាគីដែលបានស្នើសុំ នូវឯកសារចំលងនៃសំណុំលិខិត របាយការណ៍រដ្ឋបាល ឬពត៌មានដែលខ្លួនមាន ដែលនៅក្រោមច្បាប់ក្នុងស្រុករបស់ខ្លួន សាធារណៈជនទូទៅ ក៏អាចទទួលបានផងដែរនូវសំណុំឯកសារទាំងនេះ

(ខ) អាចផ្តល់តាមឆន្ទានុសិទ្ធិរបស់ខ្លួន ទៅឱ្យរដ្ឋភាគីដែលបានស្នើសុំ ទាំងមូល ជាផ្នែក ឬជាកម្មវត្ថុនៃលក្ខខណ្ឌបែបនោះ នៅពេលដែលខ្លួន យល់ឃើញថាមានការសមស្រប

នូវឯកសារចំលងនៃសំណុំលិខិតរបាយការណ៍ ឬពត៌មានរដ្ឋបាល ដែលខ្លួនមាន ឬ ដែលនៅក្រោមច្បាប់ក្នុងស្រុករបស់ខ្លួន សាធារណៈជនទូទៅ មិនអាចទទួលបានទេ នូវសំណុំឯកសារទាំងនេះ ។

៣០- រដ្ឋភាគីទាំងឡាយ ត្រូវតែពិចារណា តាមការចាំបាច់ អំពីលទ្ធភាពនៃការចុះកិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងទ្វេភាគី ឬពហុភាគី ដែលនឹងបំរើដល់គោលដៅផ្តល់អានុភាពអនុវត្តជាក់ស្តែង ឬលើកកំពស់ដល់បទបញ្ញត្តិទាំងឡាយនៃមាត្រានេះ ។

## មាត្រា ១៩

### ការស៊ើបអង្កេតរួមគ្នា:

រដ្ឋភាគីទាំងឡាយ ត្រូវតែពិចារណាអំពីការចុះកិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងទ្វេភាគី ឬពហុ ភាគី ដែលទាក់ទងជាមួយនឹងបញ្ហាទាំងឡាយ ដែលជាកម្មវត្ថុនៃការស៊ើបអង្កេត ការចោទប្រកាន់ ឬនីតិវិធីតុលាការនៅក្នុងរដ្ឋមួយ ឬរដ្ឋច្រើន អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ អាចបង្កើតអង្គការស៊ើបអង្កេតរួមគ្នាបាន។ ប្រសិនបើគ្មានកិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងបែបនេះទេនោះ ការស៊ើបអង្កេតរួមគ្នា អាចត្រូវបានសំរេចមួយករណីម្តងៗ ។ រដ្ឋភាគីដែលពាក់ព័ន្ធ ទាំងនោះត្រូវតែត្រួតពិនិត្យមើលថាអធិបតេយ្យភាពរបស់រដ្ឋភាគី ដែលការស៊ើបអង្កេតបែបនេះ នឹងត្រូវធ្វើឡើងនៅក្នុងទឹកដីនោះ ត្រូវបានគោរពយ៉ាងពេញលេញ ។

## មាត្រា ២០

### បច្ចេកទេសការស៊ើបអង្កេតពិសេស:

១- ប្រសិនបើមានការអនុញ្ញាត ដោយគោលការណ៍ជាមូលដ្ឋាននៃប្រព័ន្ធច្បាប់ក្នុងស្រុករបស់ខ្លួននោះ រដ្ឋភាគីនិមួយៗ តាមលទ្ធភាពទាំងឡាយរបស់ខ្លួន និងក្រោមលក្ខខណ្ឌទាំងឡាយដែលបានចែងដោយច្បាប់ក្នុងស្រុករបស់ខ្លួន ត្រូវតែចាត់វិធានការចាំបាច់នានា ដើម្បីអនុញ្ញាតឱ្យមានការប្រើប្រាស់ដ៏សមស្រប នូវការប្រគល់ដែលស្ថិតក្រោមការត្រួតពិនិត្យ និងបច្ចេកទេសស៊ើបអង្កេតពិសេសផ្សេងៗទៀត ដោយអាជ្ញាធរមាន សមត្ថកិច្ចរបស់ខ្លួននៅក្នុងទឹកដីរបស់ខ្លួន សំរាប់គោលបំណងនៃការប្រយុទ្ធប្រឆាំងនឹងបណ្តាញឧក្រិដ្ឋកម្ម ឱ្យមានប្រសិទ្ធិភាព នៅពេលដែលខ្លួនយល់ឃើញថាមានការសមស្រប ដូចជាការប្រើប្រាស់ការឃ្លាំមើលដោយគ្រឿងអេឡិចត្រូនិច ឬ រូបភាពឈ្លបយកការណ៍ផ្សេងៗទៀត និងប្រតិបត្តិការសំងាត់ ជាដើម ។

២- សំរាប់គោលបំណងនៃការស៊ើបអង្កេតបទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ រដ្ឋភាគីទាំងឡាយ ត្រូវបានលើកទឹកចិត្តឱ្យចុះ នៅពេលមានការចាំបាច់ នូវកិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងទ្វេភាគី ឬពហុភាគីដ៏សមស្របនានា សំរាប់ការប្រើប្រាស់បច្ចេកទេសស៊ើបអង្កេតពិសេសបែបនេះ នៅក្នុងលក្ខណៈនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ។ កិច្ចព្រមព្រៀង ឬការរៀប ចំចាត់ចែងបែបនេះ ត្រូវតែបានចុះ និងអនុវត្តន៍ ដោយស្របតាមគោលការណ៍ស្មើភាពគ្នាចំពោះអធិបតេយ្យភាពរបស់រដ្ឋទាំងឡាយឱ្យបានពេញលេញ ហើយត្រូវតែបានអនុវត្តន៍ឱ្យបានតឹងរឹងស្របតាមសេចក្តីចែងទាំងឡាយរបស់កិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងទាំងនោះ ។

៣- ប្រសិនបើគ្មានកិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងមួយ ដូចមានចែងនៅក្នុងកថាខណ្ឌទី ២ នៃមាត្រានេះទេ សេចក្តីសំរេចទាំងឡាយ ដើម្បីប្រើប្រាស់បច្ចេកទេសស៊ើបអង្កេតពិសេសបែបនេះនៅក្នុងថ្នាក់អន្តរជាតិ ត្រូវតែធ្វើឡើងតាមមូលដ្ឋានមួយករណីម្តងៗ ហើយនៅពេលមានការចាំបាច់ អាចពិចារណាអំពីការរៀប ចំចាត់ចែង និងការយោគយល់គ្នាផ្នែកហិរញ្ញវត្ថុចំពោះការអនុវត្តន៍សមត្ថកិច្ចដោយរដ្ឋភាគីដែលពាក់ព័ន្ធទាំងនោះ ។

៤- សេចក្តីសំរេចទាំងឡាយ ដើម្បីប្រើប្រាស់ការប្រគល់ស្ថិតក្រោមការត្រួតពិនិត្យនៅក្នុងថ្នាក់អន្តរជាតិ អាចរាប់បញ្ចូលទាំងវិធីសាស្ត្រនានា ដូចជា ការតាមស្ទាក់ និងការអនុញ្ញាតឱ្យទំនិញនោះបន្តដំណើរដោយមិនធ្វើអោយខូច ឬបន្ទាប់មកទៀតត្រូវបានដក ឬដាក់ជំនួសវិញទាំងមូល ឬដោយផ្នែកនូវទំនិញទាំងនោះដោយមានការយល់ព្រមពីរដ្ឋភាគី ដែលពាក់ព័ន្ធទាំងនោះ ។

## មាត្រា ២១

### ការផ្ទេរនៃនីតិវិធីព្រហ្មទណ្ឌ:

រដ្ឋភាគីទាំងឡាយ ត្រូវតែពិចារណាអំពីលទ្ធភាពនៃការផ្ទេរឱ្យគ្នាទៅវិញទៅមក នូវនីតិវិធីទាក់ទងនឹងការចោទប្រកាន់នៃបទល្មើសមួយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ នៅក្នុងករណីដែលការផ្ទេរបែបនេះត្រូវបានពិចារណាថាជាផលប្រយោជន៍នៃការគ្រប់គ្រងវិស័យយុត្តិធម៌ឱ្យបានល្អ ជាពិសេស នៅក្នុងករណីដែលមានលំដាប់យុត្តាធិការជាច្រើន មានការពាក់ព័ន្ធគ្នា ដើម្បីប្រមូលផ្តុំការចោទប្រកាន់នោះ។

## មាត្រា ២២

### ការបង្កើតកិរិយាតុលាការពីមុន

រដ្ឋភាគីនិមួយៗ អាចអនុម័តវិធានការច្បាប់ ឬវិធានការផ្សេងៗទៀត ដែលចាំបាច់ដើម្បីគិតដល់នៅក្រោមលក្ខខណ្ឌទាំងឡាយ និង សំរាប់គោលបំណងដែលខ្លួនយល់ថាមានការសមស្របការផ្តន្ទាទោស

ពីពេលមុនណាមួយរបស់ជនល្មើសម្នាក់ ដែលត្រូវបានគេសន្មត់អំពីបទល្មើស នៅក្នុងរដ្ឋមួយផ្សេងទៀត សំរាប់គោលបំណងនៃការប្រើប្រាស់ពត៌មានបែបនេះនៅក្នុងក្របខណ្ឌនៃនីតិវិធីព្រហ្មទណ្ឌ ដែលទាក់ទងជាមួយនឹងបទល្មើសមួយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ ។

## មាត្រា ២៣

### ការចោទប្រកាន់ចំពោះការរារាំងដល់ដំណើរការយុត្តិធម៌:

រដ្ឋភាគីនិមួយៗ ត្រូវតែអនុម័តវិធានការច្បាប់ ឬវិធានការផ្សេងៗទៀត ដែលចាំបាច់ដើម្បីបង្កើតឱ្យមានជាបទល្មើសព្រហ្មទណ្ឌមួយ នៅពេលដែលបទល្មើសនោះ ត្រូវបានប្រព្រឹត្តដោយចេតនាចំពោះ :

(ក) ការប្រើប្រាស់កំលាំងកាយ ការគំរាមកំហែង ឬការបំផិតបំភ័យ ឬការសន្យា ការផ្តល់ ឬឱ្យផលប្រយោជន៍ដោយមិនត្រឹមត្រូវ ដើម្បីបញ្ចុះបញ្ចូលឱ្យផ្តល់ចំលើយកសិណសាក្សីដែលក្លែងក្លាយ ឬ រារាំងការផ្តល់ចំលើយកសិណសាក្សី ឬការបង្ហាញធាតុផ្សំភស្តុតាងនៅក្នុងនីតិវិធីមួយ ដែលទាក់ទងជាមួយនឹងការប្រព្រឹត្តិបទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ

(ខ) ការប្រើប្រាស់កំលាំងកាយ ការគំរាមកំហែង ឬការបំផិតបំភ័យ រារាំងការអនុវត្តនីភារកិច្ចជាផ្លូវការដោយភ្នាក់ងារមន្ត្រីយុត្តិធម៌ ឬភ្នាក់ងារមន្ត្រីរុករក រឺបង្ក្រាប ដែលទាក់ទងជាមួយនឹងការប្រព្រឹត្តិបទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ ។ គ្មានបទបញ្ញត្តិណាមួយនៅក្នុងកថាខណ្ឌនេះ ត្រូវមានសេចក្តីធ្វើអោយប៉ះពាល់ដល់សិទ្ធិរបស់រដ្ឋភាគីទាំងឡាយ ដើម្បីមានបទបញ្ញត្តិច្បាប់ដែលការពារប្រភេទផ្សេងៗទៀតនៃភ្នាក់ងារមន្ត្រីសាធារណៈឡើយ ។

## មាត្រា ២៤

### កិច្ចការពារសាក្សី:

១- រដ្ឋភាគីនិមួយៗ ត្រូវតែចាត់វិធានការសមស្របនានា នៅក្នុងរង្វង់ដែនមធ្យោបាយរបស់ខ្លួន ដើម្បីផ្តល់កិច្ចការពារប្រកបដោយប្រសិទ្ធិភាព ពីការសងសឹក ឬការបំផិតបំភ័យទាំងឡាយ ដែលអាចមានចំពោះសាក្សីនៅក្នុងនីតិវិធិព្រហ្មទណ្ឌ ដែលបានផ្តល់ចំលើយកសិណសាក្សីពាក់ព័ន្ធជាមួយនឹងបទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ និងតាមការសមស្រប ចំពោះសាច់ញាតិរបស់ពួកគេ និងបុគ្គលផ្សេងៗទៀត ដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងសាក្សីនោះ។

២- វិធានការទាំងឡាយ ដែលចង់បានក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ អាចរាប់បញ្ចូលក្នុងនោះដោយមិនបង្ករព្យសនកម្មដល់សិទ្ធិរបស់ភាគីចុងចោទ ដោយរាប់ទាំងសិទ្ធិដើម្បីមាននិតិវិធីត្រឹមត្រូវតាមច្បាប់ផងដែរនូវ :

(ក) ការបង្កើតនីតិវិធីទាំងឡាយ សំរាប់កិច្ចការពារខាងរាងកាយរបស់បុគ្គលទាំងនោះ ដូចជា តាមការចាំបាច់ និងលទ្ធភាពដែលអាចធ្វើបាន ផ្តល់ទីលំនៅថ្មីដល់ពួកគេ និងអនុញ្ញាតទៅតាម ការសមស្រប ថានឹងមិនលាតត្រដាង ឬរឹតត្បិតទៅលើការលាតត្រដាងអំពីពត៌មាន ដែលទាក់ទងជា មួយនឹងអត្តសញ្ញាណ និងទីកន្លែងដែលបុគ្គលស្នាក់នៅ

(ខ) ការផ្តល់វិធាននៃភស្តុតាង ដើម្បីអនុញ្ញាតឱ្យសាក្សី ដែលផ្តល់ភស្តុតាងនោះស្ថិត ក្នុងលក្ខណៈមួយដែលធានាបាននូវសុវត្ថិភាពរបស់សាក្សីនោះ ដូចជា ការអនុញ្ញាត ឱ្យមានចំលើយកសិណសាក្សី តាមរយៈការភ្ជាប់ការទាក់ទងតាមរយៈវីដេអូ ឬតាមមធ្យោបាយ គ្រប់គ្រាន់ផ្សេងៗទៀត ជាដើម ។

៣- រដ្ឋភាគីទាំងឡាយ ត្រូវតែពិចារណាអំពីការចុះកិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងទាំងឡាយជាមួយ នឹងរដ្ឋភាគីផ្សេងៗទៀត សំរាប់ការផ្តល់ទីលំនៅថ្មីដល់បុគ្គលទាំងឡាយ ដែលបាននិយាយសំដៅនៅក្នុង កថាខណ្ឌទី ១ នៃមាត្រានេះ ។

៤- បទបញ្ញត្តិទាំងឡាយនៃមាត្រានេះ ត្រូវតែអនុវត្តនឹងផងដែរចំពោះជនរងគ្រោះទាំងឡាយ នៅពេលអ្នកទាំងនោះបានធ្វើជាសាក្សី ។

## មាត្រា ២៥

## ការផ្តល់ជំនួយសំរាប់ជនរងគ្រោះ និងកិច្ចការពារជនរងគ្រោះ:

១- រដ្ឋភាគីនិមួយៗ ត្រូវតែចាត់វិធានការសមស្របនានា ទៅតាមមធ្យោបាយរបស់ខ្លួន ដើម្បីផ្តល់ជំនួយ និងផ្តល់កិច្ចការពារដល់ជនរងគ្រោះនៃបទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ ជាពិសេស នៅក្នុងករណីមានការគំរាមកំហែង ដើម្បីសងសឹក ឬការបំផិតបំភ័យ ។

២- រដ្ឋភាគីនិមួយៗ ត្រូវតែបង្កើតនីតិវិធីសមស្របនានា ដើម្បីផ្តល់នូវលទ្ធភាពទទួលបានការសងជំងឺចិត្ត និង សំណងចំពោះជនរងគ្រោះនៃបទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ ។

៣- រដ្ឋភាគីនិមួយៗ ក្រោមច្បាប់ក្នុងស្រុករបស់ខ្លួន ត្រូវធ្វើយ៉ាងណាអោយមតិយោបល់ និងការខ្វល់ខ្វាយ របស់ជនរងគ្រោះ ត្រូវដាក់បង្ហាញ និងពិចារណានៅក្នុងដំណាក់កាលសមស្របនានានៃ នីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងជនល្មើស នៅក្នុងលក្ខណៈមួយដែលគ្មានព្យសនកម្មទៅលើសិទ្ធិនៃការការ ពារខ្លួនឡើយ ។

## មាត្រា ២៦

**វិធានការទាំងឡាយ ដើម្បីលើកកំពស់កិច្ចសហប្រតិបត្តិការជាមួយនឹងសេវារុករក និង បង្ក្រាបៈ**

១- រដ្ឋភាគីនីមួយៗ ត្រូវតែចាត់វិធានការសមស្របនានា ដើម្បីលើកទឹកចិត្តដល់បុគ្គលទាំងឡាយ ដែលចូលរួម ឬបានចូលរួមនៅក្នុងក្រុមបណ្ដាញឧក្រិដ្ឋជនទាំងឡាយ ដើម្បីឱ្យពួកគេៈ

(ក) ផ្ដល់ពត៌មានដែលមានសារៈប្រយោជន៍ដល់អាជ្ញាធរមានសមត្ថកិច្ច សំរាប់គោលបំណងនៃការស៊ើបអង្កេត និងរកភស្ដុតាងលើបញ្ហាបែបនេះ ដូចជាៈ

(១) អត្តសញ្ញាណ ចរិតលក្ខណៈ សមាសភាព រចនាសម្ព័ន្ធ ទីតាំង ឬសកម្មភាពរបស់ក្រុមបណ្ដាញឧក្រិដ្ឋជនទាំងឡាយ

(២) ទំនាក់ទំនង ដោយរាប់ទាំងទំនាក់ទំនងអន្តរជាតិ ដែលមានជាមួយនឹងក្រុមបណ្ដាញឧក្រិដ្ឋជនផ្សេងៗទៀត

(៣) បទល្មើសទាំងឡាយ ដែលក្រុមបណ្ដាញឧក្រិដ្ឋជនទាំងនោះ បានប្រព្រឹត្ត ឬអាចនឹងប្រព្រឹត្ត

(ខ) ផ្ដល់ជំនួយតាមការពិត និងជាក់ស្ដែងដល់អាជ្ញាធរមានសមត្ថកិច្ច ដែលអាចនឹងរួមវិភាគទានទៅដល់ការដកហូតប្រភពធនធាន ឬផលិតផលពីការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្មរបស់ក្រុមបណ្ដាញឧក្រិដ្ឋជនទាំងនោះ ។

២- រដ្ឋភាគីនីមួយៗ ត្រូវតែពិចារណាអំពីការផ្ដល់លទ្ធភាព នៅក្នុងករណីសមស្របនានា នៃការសំរាលការផ្ដន្ទាទោសដល់បុគ្គលជាប់ចោទម្នាក់ ដែលផ្ដល់កិច្ចសហប្រតិបត្តិការយ៉ាងក្រាស់ក្រែលនៅក្នុងការស៊ើបអង្កេត ឬការចោទប្រកាន់ ដែលមានចែងនៅក្នុងអនុសញ្ញា នេះ ។

៣- រដ្ឋភាគីនីមួយៗ ត្រូវតែពិចារណាអំពីការផ្ដល់លទ្ធភាព ស្របតាមគោលការណ៍ជាមូលដ្ឋាននៃច្បាប់ក្នុងស្រុករបស់ខ្លួន ការផ្ដល់អភ័យឯកសិទ្ធិពីការចោទប្រកាន់ទោស ឱ្យទៅបុគ្គលម្នាក់ដែលបានផ្ដល់កិច្ចសហប្រតិបត្តិការយ៉ាងក្រាស់ក្រែលនៅក្នុងការស៊ើបអង្កេត ឬការចោទប្រកាន់ចំពោះបទល្មើសមួយដែលមានចែងនៅក្នុងអនុសញ្ញានេះ ។

៤- កិច្ចការពារបុគ្គលបែបនេះ ត្រូវតែបានផ្ដល់ឱ្យ ដូចមានចែងនៅក្នុងមាត្រា ២៤ នៃអនុសញ្ញានេះ ។

៥- នៅពេលដែលបុគ្គលម្នាក់ ដែលបាននិយាយសំដៅនៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ដែលមានទីលំនៅស្ថិតនៅក្នុង រដ្ឋភាគីមួយ អាចផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងក្រាស់ក្រែល ដល់អាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីមួយផ្សេងទៀត រដ្ឋភាគីដែលពាក់ព័ន្ធទាំងនោះ អាចពិចារណា អំពីការចុះកិច្ចព្រមព្រៀង ឬការរៀបចំ ចាត់ចែងទាំងឡាយ ស្របតាមច្បាប់ក្នុងស្រុករបស់ខ្លួន ដែលពាក់ព័ន្ធជាមួយនឹងការផ្តល់ជាយថាហេតុ ដោយរដ្ឋភាគីផ្សេងៗទៀតអំពីការការពារ ដែលបានចែង នៅក្នុងកថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ នៃមាត្រានេះ ។

## មាត្រា ២៧

## កិច្ចសហប្រតិបត្តិការរវាងសេវារុករក និង សេវាបង្ក្រាប:

១- រដ្ឋភាគីទាំងឡាយ ត្រូវតែធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នាឱ្យជិតស្និទ្ធ ស្របទៅតាមប្រព័ន្ធគតិយុត្តិ និងរដ្ឋបាលក្នុងរដ្ឋរបស់ខ្លួននិមួយៗ ដើម្បីពង្រឹងប្រសិទ្ធិភាពនៃការរុករក នឹង បង្ក្រាប បទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ ។ រដ្ឋភាគីនិមួយៗ ជាពិសេស ត្រូវតែអនុម័តវិធានការប្រកបដោយប្រសិទ្ធិភាពទាំងឡាយ ដើម្បី:

(ក) ពង្រឹង រឺតាមការចាំបាច់ បង្កើតបណ្តាញទូរគមនាគមន៍រវាងអាជ្ញាធរមានសមត្ថកិច្ច អង្គការនិងសេវាទាំងឡាយរបស់ខ្លួន ដើម្បីសំរបសំរួលដល់ការផ្លាស់ប្តូរគ្នាដោយ សុវត្ថិភាព និងឆាប់រហ័សនូវពត៌មាន ដែលទាក់ទងជាមួយនឹងទិដ្ឋភាពទាំងអស់នៃបទល្មើស ទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ ដោយរាប់ទាំងទំនាក់ទំនងភ្ជាប់ជាមួយនឹង សកម្មភាព ឧក្រិដ្ឋកម្មផ្សេងៗទៀតផងដែរ ប្រសិនបើរដ្ឋភាគីដែលពាក់ព័ន្ធទាំងនោះ យល់ថាមាន ការសមស្រប

(ខ) ធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងរដ្ឋភាគីផ្សេងៗទៀត ចំពោះបទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះក្នុងការស៊ើបអង្កេត ទាក់ទងជាមួយនឹងចំនុចដូចខាងក្រោម:

(១) អត្តសញ្ញាណ និងសកម្មភាពរបស់បុគ្គល ដែលជាប់សង្ស័យ ពីបទពាក់ព័ន្ធជាមួយនឹងបទល្មើសបែបនោះ ឬទីកន្លែងរបស់បុគ្គលពាក់ព័ន្ធផ្សេងៗ ទៀត

(២) ចលនានៃផលិតផលបានពីការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្ម ឬទ្រព្យសម្បត្តិដែលបាន មកពីការប្រព្រឹត្តិបទល្មើសបែបនេះ

(៣) ចលនានៃទ្រព្យសម្បត្តិ សំភារៈ ឬមធ្យោបាយផ្សេងៗទៀត ដែលបានប្រើប្រាស់ ឬមានបំណងដើម្បីប្រើប្រាស់នៅក្នុងការប្រព្រឹត្តិបទល្មើសបែបនេះ

(គ) ផ្តល់ នៅពេលដែលមានទូវវត្ថុ ឬបរិមាណនៃសារធាតុចាំបាច់ទាំងឡាយ សំរាប់គោលបំណងនៃការវិភាគ និងការស៊ើបអង្កេត

(ឃ) ធ្វើអោយងាយស្រួលដល់ការសំរបសំរួលប្រកបដោយប្រសិទ្ធិភាពរវាងអាជ្ញាធរមានសមត្ថកិច្ច អង្គការ និងសេវាទាំងឡាយរបស់ខ្លួន និងលើកកំពស់ការផ្លាស់ប្តូបុគ្គលិក និងអ្នកជំនាញការផ្សេងៗទៀត ដោយរាប់ទាំងការដាក់ឱ្យនៅក្រៅតំណែងរបស់មន្ត្រីទំនាក់ទំនង ក្រោមកិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងទ្វេភាគីទាំងឡាយ រវាងរដ្ឋភាគីដែលពាក់ព័ន្ធទាំងនោះ ។

(ង) ផ្លាស់ប្តូរពត៌មានជាមួយនឹងរដ្ឋភាគីផ្សេងៗទៀត ស្តីពីមធ្យោបាយ និងវិធីសាស្ត្រជាក់លាក់ដែលបានប្រើប្រាស់ដោយក្រុមបណ្តាញឧក្រិដ្ឋជនទាំងឡាយ ដោយរាប់ទាំង តាមការអនុវត្តន៍ទៅបាន ដូចជា ផ្លូវ និងមធ្យោបាយធ្វើដំណើរ និងការប្រើប្រាស់អត្តសញ្ញាណក្លែងបន្លំ ឯកសារដែលគេកែប្រែ ឬ ក្លែងបន្លំ ឬមធ្យោបាយផ្សេងៗទៀតនៃការលាក់កំបាំងសកម្មភាពរបស់ខ្លួន ។

(ច) ផ្លាស់ប្តូរពត៌មាន និងសំរបសំរួលលើវិធានការរដ្ឋបាល និងវិធានការផ្សេងៗទៀតដែលបានចាត់ធ្វើ តាមការសមស្រប សំរាប់គោលបំណងរុករកបទល្មើសទាំងឡាយអោយបានឆាប់ ដែលមានចែងនៅក្នុងអនុសញ្ញានេះ ។

២- ក្នុងគោលបំណងផ្តល់អានុភាពចំពោះអនុសញ្ញានេះ រដ្ឋភាគីទាំងឡាយ ត្រូវតែពិចារណាអំពីការចុះកិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងទ្វេភាគី ឬពហុភាគីស្តីពីកិច្ចសហប្រតិបត្តិការដោយផ្ទាល់រវាងសេវារុករក និង បង្ក្រាបទាំងឡាយរបស់ខ្លួន និងកិច្ចព្រមព្រៀងកិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងនោះ ប្រសិនបើមានកិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងបែបនោះរួចហើយ ។ បើគ្មានកិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងបែបនោះរវាង រដ្ឋភាគីដែលពាក់ព័ន្ធទេនោះ រដ្ឋភាគីទាំងនោះ អាចឈរលើមូលដ្ឋានអនុសញ្ញានេះ ដើម្បីបង្កើតកិច្ចសហប្រតិបត្តិការនៅក្នុងការរុករក និងបង្ក្រាបបទល្មើសទាំងឡាយ ដែលបានលើកឡើងដោយអនុសញ្ញានេះ ។ តាមការសមស្រប រដ្ឋភាគីទាំងឡាយ ត្រូវតែប្រើប្រាស់កិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងឱ្យបានពេញ លេញ

ដោយរាប់ទាំងអង្គការអន្តរជាតិ ឬអង្គការក្នុងតំបន់ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការរវាងសេវាកុករក និង បង្ក្រាបទាំងឡាយរបស់ខ្លួន ។

៣- រដ្ឋភាគីទាំងឡាយ ត្រូវតែខិតខំប្រឹងប្រែងធ្វើកិច្ចសហប្រតិបត្តិការ នៅក្នុងវង្វង់មធ្យោបាយរបស់ខ្លួន ក្នុងការប្រឈមមុខនឹងបណ្តាញអំពើឧក្រិដ្ឋកម្មឆ្លងដែន ដែលត្រូវបានប្រព្រឹត្តឡើងតាមរយៈនៃការប្រើប្រាស់បច្ចេកវិជ្ជាទំនើបទាន់សម័យ ។

## មាត្រា ២៨

### ការប្រមូល ការផ្លាស់ប្តូរ និងការវិភាគពត៌មានអំពីចរិតលក្ខណៈរបស់បណ្តាញអំពើឧក្រិដ្ឋកម្មៈ

១- រដ្ឋភាគីនិមួយៗ ត្រូវតែពិចារណាអំពីការវិភាគ ដោយពិគ្រោះយោបល់ជាមួយនឹងមជ្ឈដ្ឋានវិទ្យាសាស្ត្រ និងសិក្សាស្រាវជ្រាវ អំពីនិន្នាការរបស់បណ្តាញអំពើឧក្រិដ្ឋកម្មនៅក្នុងទឹកដីរបស់ខ្លួន កាលៈទេសៈ ដែលបណ្តាញអំពើឧក្រិដ្ឋកម្ម បានធ្វើប្រតិបត្តិការ ក៏ដូចជាជាមួយនឹងក្រុមអ្នកជំនាញឯកទេស និងបច្ចេកវិជ្ជា ដែលពាក់ព័ន្ធទាំងឡាយ ផងដែរ ។

២- រដ្ឋភាគីទាំងឡាយ ត្រូវតែពិចារណាអំពីការអភិវឌ្ឍន៍ និងការចែករំលែកបច្ចេកទេសខាងការវិភាគ ដែលពាក់ព័ន្ធនឹងសកម្មភាពរបស់បណ្តាញអំពើឧក្រិដ្ឋកម្មជាមួយគ្នា និងតាមរយៈអង្គការអន្តរជាតិ និងអង្គការក្នុងតំបន់នានា ។ សំរាប់គោលបំណងនេះ និយមន័យ បទដ្ឋាន និងវិធីសាស្ត្ររួមមួយ ត្រូវតែបានបង្កើតឡើង និងយកទៅអនុវត្តន៍ឱ្យបានសមស្រប ។

៣- រដ្ឋភាគីនិមួយៗ ត្រូវតែពិចារណាអំពីការត្រួតពិនិត្យមើលគោលនយោបាយ និងវិធានការជាក់ស្តែងរបស់ខ្លួន ដើម្បីប្រយុទ្ធប្រឆាំងនឹងបណ្តាញអំពើឧក្រិដ្ឋកម្ម និងធ្វើការវាយតំលៃលើប្រសិទ្ធិភាព និងសមត្ថភាព ផងដែរ ។

## មាត្រា ២៩

### ការបណ្តុះបណ្តាល និងជំនួយផ្នែកបច្ចេកទេសៈ

១- រដ្ឋភាគីនិមួយៗ តាមការចាំបាច់ ត្រូវតែផ្តួចផ្តើម បង្កើត និងកែលំអរកម្មវិធីបណ្តុះបណ្តាលជាក់លាក់ទាំងឡាយ សំរាប់មន្ត្រីនៃសេវាកុករក និង បង្ក្រាបរបស់ខ្លួន ដោយរាប់ទាំងព្រះរាជអាជ្ញា

ចៅក្រមស៊ើបអង្កេត និង មន្ត្រីផ្នែកពន្ធដារ និងមន្ត្រីផ្សេងៗទៀត ដែលទទួលបន្ទុកលើការទប់ស្កាត់ ការតុរករក និងការទប់ស្កាត់លើបទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ ។ កម្មវិធីបណ្តុះបណ្តាលបែបនេះ អាចរាប់បញ្ចូលការដាប់អោយនៅក្រៅក្របខ័ណ្ឌ និងការផ្លាស់ប្តូរ មន្ត្រីផងដែរ ។ កម្មវិធីបែបនេះ ជាពិសេស និងតាមការអនុញ្ញាតដោយច្បាប់ក្នុងស្រុក ត្រូវតែ ដោះស្រាយលើបញ្ហាទាំងឡាយ ដូចខាង ក្រោមនេះ:

(ក) វិធីសាស្ត្រ ដែលបានប្រើប្រាស់នៅក្នុងការទប់ស្កាត់ ការរុករក និងការបង្ក្រាបទៅលើ បទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ

(ខ) ផ្លូវ និងបច្ចេកទេស ដែលបានប្រើប្រាស់ដោយបុគ្គលទាំងឡាយ ដែលត្រូវបានសង្ស័យ ពីបទពាក់ព័ន្ធនៅក្នុងបទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ ដោយរាប់ទាំង នៅក្នុងបណ្តារដ្ឋឆ្លងកាត់ និងវិធានការប្រយុទ្ធប្រឆាំងទាំងឡាយ ដែលមានលក្ខណៈសមស្រប

(គ) ការត្រួតពិនិត្យមើលចលនានៃទំនិញរត់ពន្ធទាំងឡាយ

(ឃ) ការរុករក និងការត្រួតពិនិត្យមើលចលនានៃផលិតផលពីការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្ម ទ្រព្យសម្បត្តិ សំភារៈ ឬឧបករណ៍ផ្សេងៗទៀត និងវិធីសាស្ត្រ ដែលបានប្រើប្រាស់សំរាប់ ការផ្ទេរ ការលាក់កំបាំង ឬការក្លែងបន្លំផលិតផលពីការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្ម ទ្រព្យសម្បត្តិ សំភារៈបែបនេះ ឬឧបករណ៍ផ្សេងៗទៀត ក៏ដូចជាវិធីសាស្ត្រទាំងឡាយ ដែលបានប្រើ ប្រាស់នៅក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើលាងលុយកខ្វក់ និងអំពើឧក្រិដ្ឋកម្មផ្នែកហិរញ្ញវត្ថុ ផ្សេងៗទៀត

(ង) ការប្រមូលធាតុផ្សំនៃភស្តុតាង

(ច) បច្ចេកទេសត្រួតពិនិត្យនៅក្នុងតំបន់ពាណិជ្ជកម្មសេរី និងបណ្តាកំពង់ផែសេរីនានា

(ឆ) សំភារៈ និងបច្ចេកទេសទំនើបទាន់សម័យ សំរាប់រុករក និង បង្ក្រាប ដោយរាប់ទាំងការឃ្លាំមើលផ្នែកអេឡិចត្រូនិច ការប្រគល់ដែលស្ថិតក្រោមការត្រួតពិនិត្យ និងប្រតិបត្តិការបញ្ចូលខ្លួនទាំងឡាយ

(ជ) វិធីសាស្ត្រ ដែលបានប្រើប្រាស់នៅក្នុងប្រយុទ្ធប្រឆាំងនឹងបណ្តាញអំពើឧក្រិដ្ឋកម្មឆ្លងដែន ដែលបានប្រព្រឹត្តតាមរយៈនៃការប្រើប្រាស់ម៉ាស៊ីនកុំព្យូទ័រ បណ្តាញទូរគមនាគមន៍ ឬរូបភាពផ្សេងៗទៀតនៃបច្ចេកវិជ្ជាទំនើបទាន់សម័យ និង

(ឈ) វិធីសាស្ត្រ ដែលបានប្រើប្រាស់នៅក្នុងកិច្ចការពារជនរងគ្រោះ និងសាក្សីទាំងឡាយ ។

២- រដ្ឋភាគីទាំងឡាយ ត្រូវតែជួយគ្នាទៅវិញទៅមកនៅក្នុងការធ្វើផែនការ និងការអនុវត្តនីកម្មវិធីស្រាវជ្រាវ និង បណ្តុះបណ្តាល ដែលបានបង្កើតឡើងដើម្បីចែករំលែកជំនាញឯកទេសនៅក្នុងផ្នែកទាំងឡាយ ដែលបាននិយាយសំដៅនៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ហើយត្រូវតែប្រើប្រាស់ផងដែរ នៅពេល មានការសមស្រប នូវសន្និសីទ និងសិក្ខាសាលាទាំងឡាយក្នុងតំបន់ និងអន្តរជាតិ ដើម្បីលើកកំពស់កិច្ច សហប្រតិបត្តិការ និងជំរុញការពិភាក្សាអំពីបញ្ហាទាំងឡាយនៃការខ្វល់ខ្វាយរួមគ្នា ដោយរាប់ទាំងបញ្ហា និងតំរូវការពិសេសៗទាំងឡាយរបស់បណ្តារដ្ឋ ដែលជាទីកន្លែងឆ្លងកាត់ផងដែរ ។

៣- រដ្ឋភាគីទាំងឡាយ ត្រូវតែលើកកំពស់ការបណ្តុះបណ្តាល និងជំនួយផ្នែកបច្ចេកទេស ដែលនឹងសំរបសំរួលដល់ការធ្វើបត្យាប័ន និងជំនួយផ្នែកច្បាប់ទៅវិញទៅមក ។ សកម្មភាពបណ្តុះបណ្តាល និងជំនួយផ្នែកបច្ចេកទេសបែបនេះ អាចរាប់បញ្ចូលការបណ្តុះបណ្តាលផ្នែកភាសា ការដាក់អោយមន្ត្រីនៅក្រៅក្របខ័ណ្ឌដើម និងការផ្លាស់ប្តូរនានារវាងមន្ត្រីនៅក្នុងអាជ្ញាធរ ឬទីភ្នាក់ងារថ្នាក់កណ្តាលទាំងឡាយ ដែលមានការទទួលខុស ត្រូវពាក់ព័ន្ធជាមួយនឹងការងារនេះ ។

៤- នៅក្នុងករណីមានកិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងទ្វេភាគី និងពហុភាគីនោះ ដែលកំពុងជាធរមាន រដ្ឋភាគីទាំងឡាយ ត្រូវតែពង្រឹង តាមការចាំបាច់ នូវកិច្ចប្រឹងប្រែងនានាដើម្បីបង្កើនជាអតិបរិមាចំពោះសកម្មភាពធ្វើប្រតិ បត្តិការ និងបណ្តុះបណ្តាលនៅក្នុងរង្វង់អង្គការអន្តរជាតិ និង អង្គការក្នុងតំបន់ និងនៅក្នុងរង្វង់កិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងទ្វេភាគី និងពហុភាគី ដែលមានការពាក់ព័ន្ធផ្សេងៗទៀត ។

មាត្រា ៣០

**វិធានការផ្សេងៗទៀតៈ**

**ការអនុវត្តន៍អនុសញ្ញានេះ តាមរយៈការអភិវឌ្ឍន៍សេដ្ឋកិច្ច និងជំនួយផ្នែកបច្ចេកទេសៈ**

១- រដ្ឋភាគីទាំងឡាយ ត្រូវតែចាត់វិធានការនានា ដែលធានាការអនុវត្តន៍អនុសញ្ញានេះឱ្យបាន ប្រសើរបំផុត តាមលទ្ធភាពដែលអាចធ្វើបាន តាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ ដោយពិចារណា អំពីផលប៉ះពាល់អវិជ្ជមានទាំងឡាយនៃបណ្តាញអំពើឧក្រិដ្ឋកម្មទៅលើសង្គមជាទូទៅ ជាពិសេសទៅ លើការអភិវឌ្ឍន៍ចិរកាល។

២- រដ្ឋភាគីទាំងឡាយ ត្រូវតែខិតខំប្រឹងប្រែងឱ្យបានជាក់ស្តែង តាមលទ្ធភាពដែលអាចធ្វើបាន និង ដោយមានការសំរបសំរួលជាមួយគ្នា ក៏ដូចជាជាមួយនឹងអង្គការអន្តរជាតិ និងអង្គការក្នុងតំបន់ទាំង ឡាយ ផងដែរ ដើម្បីៈ

(ក) លើកកំពស់កិច្ចសហប្រតិបត្តិការរបស់ខ្លួន នៅក្នុងថ្នាក់ផ្សេងៗជាមួយនឹងបណ្តាប្រទេស កំពុងអភិវឌ្ឍន៍នានា ក្នុងន័យដើម្បីពង្រឹងសមត្ថភាពរបស់បណ្តារប្រទេសទាំងនេះ នៅក្នុងការ ទប់ស្កាត់ និងការ ប្រយុទ្ធប្រឆាំងនឹងបណ្តាញអំពើឧក្រិដ្ឋកម្មឆ្លងដែន

(ខ) បង្កើនជំនួយផ្នែកហិរញ្ញវត្ថុ និងសំភារៈ ដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ទាំងឡាយ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងនានារបស់ខ្លួន ដើម្បីប្រយុទ្ធប្រឆាំងនឹងបណ្តាញ អំពើឧក្រិដ្ឋកម្មឆ្លងដែនឱ្យមានប្រសិទ្ធិភាព និង ដើម្បីជួយដល់ពួកគេនៅក្នុងការអនុវត្តន៍ អនុសញ្ញានេះ ឱ្យបានជោគជ័យ

(គ) ផ្តល់ជំនួយផ្នែកបច្ចេកទេសដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងបណ្តាប្រទេស ដែលមាន សេដ្ឋកិច្ច ស្ថិតក្នុងរយៈពេលអន្តរកាល ដើម្បីជួយដល់ពួកគេនៅក្នុងបំពេញតំរូវការរបស់ខ្លួន សំរាប់ការអនុវត្តន៍អនុសញ្ញានេះ ។ ដើម្បីធ្វើរឿងនេះ រដ្ឋភាគីទាំងឡាយ ត្រូវតែខិតខំប្រឹងប្រែង ដើម្បីរួមវិភាគទានឱ្យបានគ្រប់គ្រាន់ និងដោយស្ម័គ្រចិត្តជាទៀងទាត់ ទៅក្នុងគណនីមួយ ដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងនេះ ក្នុងក្របខ័ណ្ឌយន្តការមូលនិធិមួយរបស់ អង្គការសហប្រជាជាតិ ។ រដ្ឋភាគីទាំងឡាយ អាចផ្តល់ការពិចារណាជាពិសេសផងដែរ ដោយស្របតាមច្បាប់ក្នុងស្រុករបស់ខ្លួន និងបទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ អំពីការរួមវិភាគទានទៅក្នុងគណនី ដែលបាន លើកឡើងខាងលើនេះ នូវចំនួនភាគរយមួយនៃមូលនិធិ ឬតំលៃ ឆ្លើយតបមួយនៃផលិតផល

ពីការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្ម ឬទ្រព្យសម្បត្តិ ដែលត្រូវបានដកហូត ស្របតាមបទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ

(ឃ) លើកទឹកចិត្ត និងបញ្ចុះបញ្ចូលបណ្តារដ្ឋ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗទៀត តាមការសមស្រប ដើម្បីឱ្យចូលរួមជាមួយនឹងខ្លួននៅក្នុងកិច្ចប្រឹងប្រែង ស្របតាមមាត្រានេះ ជាពិសេស ដោយផ្តល់កម្មវិធីបណ្តុះបណ្តាលឱ្យបានច្រើន និង សំភារៈទំនើបទាន់សម័យឱ្យទៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នានា ដើម្បីជួយដល់ពួកគេនៅក្នុងការសំរេចបាននូវទិសដៅនៃអនុសញ្ញានេះ ។

៣- តាមលទ្ធភាពដែលអាចធ្វើទៅបាន វិធានការទាំងនេះ មិនត្រូវធ្វើអោយបង្ករអោយមានព្យសនកម្មដល់ការសន្យា ផ្តល់ជំនួយបរទេសដែលមានស្រាប់ ឬទៅលើការរៀបចំចាត់ចែង នៃកិច្ចសហប្រតិបត្តិការផ្នែកហិរញ្ញវត្ថុ ផ្សេងៗទៀតនៅថ្នាក់ទ្វេភាគី ថ្នាក់តំបន់ ឬថ្នាក់អន្តរជាតិឡើយ ។

៤- រដ្ឋភាគីទាំងឡាយ អាចចុះកិច្ចព្រមព្រៀង ឬការរៀបចំចាត់ចែងទ្វេភាគី ឬពហុភាគីស្តីពីជំនួយផ្នែកសំភារៈ និងភស្តុភារ ដោយពិចារណាអំពីការរៀបចំចាត់ចែងផ្នែកហិរញ្ញវត្ថុ ដែលចាំបាច់សំរាប់ជាមធ្យោបាយនៃកិច្ចសហប្រតិបត្តិការជាអន្តរជាតិ ដែលមានចែងក្នុងអនុសញ្ញានេះ ឱ្យមានប្រសិទ្ធិភាព និងសំរាប់ការទប់ស្កាត់ ការរុករក និងប្រយុទ្ធប្រឆាំងបណ្តាញអំពើឧក្រិដ្ឋកម្មឆ្លងដែន ។

**មាត្រា ៣១**

**ការទប់ស្កាត់:**

១- រដ្ឋភាគីទាំងឡាយ ត្រូវខិតខំប្រឹងប្រែងដើម្បីតាក់តែង និងវាយតំលៃគំរោងថ្នាក់ជាតិទាំងឡាយ និងដាក់អោយដំណើរការ និងលើកកំពស់ការអនុវត្តន៍ និងគោលនយោបាយល្អៗ ក្នុងគោលបំណងទប់ស្កាត់បណ្តាញអំពើឧក្រិដ្ឋកម្មឆ្លងដែន ។

២- រដ្ឋភាគីទាំងឡាយ ត្រូវខិតខំប្រឹងប្រែង ស្របតាមគោលការណ៍ជាមូលដ្ឋាននានានៃច្បាប់ក្នុងស្រុករបស់ខ្លួន ដើម្បីកាត់បន្ថយឱកាសដែលមានស្រាប់ ឬឱកាសទៅអនាគតសំរាប់ក្រុមបណ្តាញឧក្រិដ្ឋជន បានចូលរួមនៅក្នុងទីផ្សារស្របច្បាប់ ចំពោះផលិតផលពីការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្ម តាមរយៈវិធានការផ្នែកនីតិបញ្ញត្តិ វិធានផ្នែករដ្ឋបាល ឬវិធានការផ្សេងៗទៀតដ៏សមស្រប ។ វិធានការទាំងនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើ:

(ក) ការពង្រឹងកិច្ចសហប្រតិបត្តិការរវាងសេវារុករក និង បង្ក្រាបនានា ឬរវាងព្រះរាជអាជ្ញា និង អង្គភាពឯកជនទាំងឡាយ ដោយរាប់ទាំងផ្នែកឧស្សាហកម្មផងដែរ

(ខ) ការលើកកំពស់ការតាក់តែងបទដ្ឋាន និងនីតិវិធីទាំងឡាយ ដែលបានបង្កើតឡើងដើម្បីការពារសម្បូរភាពរបស់អង្គភាពសាធារណៈ និងអង្គភាពឯកជនទាំងឡាយដែលពាក់ព័ន្ធ ក៏ដូចជាក្រមសីលធម៌ នៃវិជ្ជាជីវៈទាំងឡាយដែលពាក់ព័ន្ធ ជាពិសេស មេធាវី សារការី ទីប្រឹក្សាសាធារណៈ ទីប្រឹក្សាផ្នែកពន្ធដារ និងទីប្រឹក្សាផ្នែកគណនេយ្យករ ជាដើម

(គ) ការទប់ស្កាត់ការប្រើប្រាស់មិនត្រឹមត្រូវដោយក្រុមបណ្តាញឧក្រិដ្ឋជន នូវនីតិវិធីដេញថ្លៃទាំងឡាយ ដែលបានអនុវត្តន៍ដោយអាជ្ញាធរសាធារណៈ និងប្រាក់ឧបត្ថម្ភ និងអាជ្ញាប័ណ្ណទាំងឡាយ ដែលបានផ្តល់ដោយអាជ្ញាធរសាធារណៈ សំរាប់សកម្មភាពពាណិជ្ជកម្ម

(ឃ) ការទប់ស្កាត់ការប្រើប្រាស់មិនត្រឹមត្រូវនូវនីតិបុគ្គល ដោយក្រុមបណ្តាញឧក្រិដ្ឋជន វិធានការបែបនេះ អាចនឹងត្រូវរាប់បញ្ចូលទាំងៈ

(១) ការបង្កើតសៀវភៅបញ្ជីជាសាធារណៈស្តីពីនីតិបុគ្គល និងរូបវន្តបុគ្គលដែលមានការ ពាក់ព័ន្ធនៅក្នុងការបង្កើត ការចាត់ចែងគ្រប់គ្រង និងការផ្តល់មូលនិធិដល់នីតិបុគ្គល ទាំងឡាយ

(២) ការដាក់ការអនុវត្តន៍នូវលទ្ធភាពនៃការធ្វើអោយប្រាសចាលសិទ្ធិ ដោយដីកាតុលាការ ឬតាមមធ្យោបាយសមស្របណាមួយ សំរាប់រយៈពេលសមស្របមួយចំពោះបុគ្គល ដែលត្រូវបានកាត់ទោសចំពោះបទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ ពីការដឹកនាំនីតិបុគ្គល ដែលបានបង្កើតឡើងនៅក្នុងរង្វង់នៃដែនដីរបស់ខ្លួននោះ

(៣) ការបង្កើតសៀវភៅបញ្ជីថ្នាក់ជាតិស្តីពីបុគ្គល ដែលត្រូវបានប្រាសចាកសិទ្ធិពីការដឹកនាំនីតិបុគ្គល និង

(៤) ការផ្លាស់ប្តូរពត៌មាន ដែលមាននៅក្នុងសៀវភៅបញ្ជីទាំងនោះ ដែលបាននិយាយសំដៅនៅក្នុងកថាខណ្ឌរងចំនុច (ឃ) ចំនុច (១) និងចំនុច (៣) នៃកថាខណ្ឌនេះជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋភាគីផ្សេងៗទៀត ។

៣- រដ្ឋភាគីទាំងឡាយ ត្រូវតែខិតខំប្រឹងប្រែងដើម្បីលើកកំពស់ការធ្វើសមាហរណកម្មចូលទៅក្នុងសង្គមវិញ ចំពោះបុគ្គលទាំងឡាយ ដែលត្រូវបានកាត់ទោសពីបទល្មើសទាំងឡាយ ដែលមានចែងនៅក្នុងអនុសញ្ញានេះ ។

៤- រដ្ឋភាគីទាំងឡាយ ត្រូវតែខិតខំប្រឹងប្រែងដើម្បីវាយតំលៃដោយទៀងពេល ទៅលើមធ្យោបាយគតិយុត្តិ និងការអនុវត្តន៍ផ្នែករដ្ឋបាលនានា ដើម្បីកំណត់ថាតើមានចំណុច ដែលខ្វះខាត ដែលនាំអោយមានការប្រើប្រាស់មិនត្រឹមត្រូវ ដោយក្រុមបណ្តាញឧក្រិដ្ឋជនរឺទេ ។

៥- រដ្ឋភាគីទាំងឡាយ ត្រូវតែខិតខំប្រឹងប្រែងដើម្បីលើកកំពស់ការយល់ដឹងរបស់សាធារណៈជន ទាក់ទងនឹងបុព្វហេតុ និងភាពធ្ងន់ធ្ងរ និងការគំរាមកំហែង ដែលបានធ្វើឡើងដោយក្រុមបណ្តាញអំពើឧក្រិដ្ឋកម្មឆ្លងដែន ។ ពត៌មាន អាចត្រូវបានផ្សព្វផ្សាយ តាមការសមស្រប តាមរយៈប្រព័ន្ធឃោសនាមហាជន និងចាត់វិធានការទាំងឡាយ ដើម្បីលើកកំពស់ការចូលរួមរបស់សាធារណៈជន នៅក្នុងការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងនឹងអំពើឧក្រិដ្ឋកម្មបែបនេះ ។

៦- រដ្ឋភាគីនិមួយៗ ត្រូវតែជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ នូវឈ្មោះ និងអាស័យដ្ឋាន នៃអាជ្ញាធរ ឬអាជ្ញាធរទាំងឡាយ ដែលអាចជួយដល់រដ្ឋភាគីផ្សេងៗទៀត នៅក្នុងការបង្កើតឡើងនូវវិធានការទាំងឡាយ ដើម្បីទប់ស្កាត់បណ្តាញអំពើឧក្រិដ្ឋកម្មឆ្លងដែន ។

៧- រដ្ឋភាគីទាំងឡាយ តាមការសមស្រប ត្រូវតែសហការជាមួយគ្នា និងជាមួយនឹងអង្គការអន្តរជាតិ និងអង្គការក្នុងតំបន់ដែលមានការពាក់ព័ន្ធ ដើម្បីលើកកំពស់ និងបង្កើតឡើងនូវវិធានការទាំងឡាយ ដែលបាននិយាយសំដៅនៅក្នុងមាត្រានេះ ។ ការធ្វើសហការនេះ រាប់បញ្ចូលទាំងការចូលរួមនៅក្នុងគំរោងការអន្តរជាតិទាំងឡាយ ដែលមានគោលបំណងទប់ស្កាត់បណ្តាញអំពើឧក្រិដ្ឋកម្មឆ្លងដែន ឧទាហរណ៏: ដោយសកម្មភាពលើកគ្គានានា ដែលធ្វើឱ្យក្រុមបុគ្គលទាំងឡាយ ដែលលែងមានភាពសំខាន់នៅក្នុងសង្គម ដែលទទួលរងពីសកម្មភាពនៃអំពើឧក្រិដ្ឋកម្មឆ្លងដែន ។

## មាត្រា ៣២

### សន្និសីទរបស់ភាគីទាំងឡាយនៃអនុសញ្ញានេះ:

១- សន្និសីទមួយរបស់ភាគីទាំងឡាយនៃអនុសញ្ញានេះ ត្រូវបានប្រារព្ធធ្វើឡើង ដើម្បីធ្វើឱ្យប្រសើរឡើងដល់សមត្ថភាពរបស់រដ្ឋភាគីទាំងនោះ ដើម្បីប្រយុទ្ធប្រឆាំងនឹងបណ្តាញអំពើឧក្រិដ្ឋកម្មឆ្លងដែន និងដើម្បីលើកកំពស់ និងត្រួតពិនិត្យមើលឡើងវិញលើការអនុវត្តន៍អនុសញ្ញានេះ ។

២- អគ្គលេខាធិការអង្គការសហប្រជាជាតិ កោះប្រជុំសន្និសីទរបស់ភាគីនេះ នៅក្នុងរយៈពេលមិន ឱ្យហួសពី ១ ឆ្នាំ បន្ទាប់ពីអនុសញ្ញានេះ បានចូលជាធរមាន ។ សន្និសីទរបស់ភាគីនេះ ត្រូវតែ អនុម័តបទបញ្ជាផ្ទៃក្នុង និងវិធានផ្នែកគ្រប់គ្រងសកម្មភាពទាំងឡាយ ដែលបានចែងនៅក្នុង កថាខណ្ឌ ទី ៣ និងកថាខណ្ឌទី ៤ នៃមាត្រានេះ (ដោយរាប់ទាំងវិធានទាំងឡាយ ដែលពាក់ព័ន្ធជាមួយ នឹងការចេញថ្លៃចំណាយផ្សេងៗ ដែលពាក់ព័ន្ធនឹងការអនុវត្តន៍សកម្មភាពទាំងនោះផងដែរ) ។

៣- សន្និសីទរបស់រដ្ឋភាគីនេះ ត្រូវតែព្រមព្រៀងគ្នាលើយន្តការទាំងឡាយ ដើម្បីសំរេចបាននូវទិសដៅ ដែល បានលើកឡើងនៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ដែលរួមមាន:

(ក) ការសំរបសំរួលលើសកម្មភាពនានា ដោយរដ្ឋភាគីទាំងឡាយនៅក្រោមមាត្រា ២៩ មាត្រា ៣០ និងមាត្រា ៣១ នៃអនុសញ្ញានេះ ដោយលើកទឹកចិត្តឱ្យមានការប្រមែប្រមូលការចូល រួមវិភាគទានទាំងឡាយ ដោយស្ម័គ្រចិត្តផងដែរ

(ខ) ការសំរបសំរួលលើការផ្លាស់ប្តូរពត៌មាន នៅក្នុងចំណោមរដ្ឋភាគីទាំងឡាយ អំពីចរិកលក្ខណៈ និងនិន្នាការនៅក្នុងបណ្តាញ អំពើឧក្រិដ្ឋកម្មឆ្លងដែន និងអំពីការអនុវត្តន៍ ដោយប្រសិទ្ធភាពនៅក្នុងការប្រ យុទ្ធប្រឆាំងនឹងបណ្តាញអំពើឧក្រិដ្ឋកម្មឆ្លងដែននេះ

(គ) ការធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការអន្តរជាតិ និងអង្គការក្នុងតំបន់ទាំងឡាយ ដែលពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ

(ឃ) ការត្រួតពិនិត្យមើលឡើងវិញ ក្នុងរយៈពេលជាទៀងទាត់ ទៅលើការអនុវត្តន៍អនុសញ្ញា នេះ

(ង) ការផ្តល់អនុសាសន៍ទាំងឡាយ ដើម្បីធ្វើអោយប្រសើរឡើងអនុសញ្ញានេះ និង ការអនុវត្តន៍អនុសញ្ញានេះ ផងដែរ ។

៤- សំរាប់គោលបំណងរបស់កថាខណ្ឌទី ៣ ចំនុច (ឃ) និងចំនុច (ង) នៃអនុសញ្ញានេះ សន្និសីទរបស់ រដ្ឋភាគីនេះ សាកសួរអំពីវិធានការទាំងឡាយ ដែលចាត់ធ្វើឡើងដោយ បណ្តារដ្ឋភាគីទាំងនោះ នៅក្នុងការអនុវត្តន៍អនុសញ្ញានេះ និងការលំបាកនានា ដែលពួកគេបានប្រឈម មុខនៅក្នុងការអនុវត្តន៍ តាមរយៈពត៌មាន ដែលបានផ្តល់ដោយរដ្ឋភាគីនោះ និងតាមរយៈយន្តការត្រួតពិនិត្យ មើលឡើងវិញជាបន្ថែមទៀតបែបនេះ ដែលអាចត្រូវបានបង្កើតឡើងដោយសន្និសីទរបស់រដ្ឋភាគីនេះ ។

៥- រដ្ឋភាគីនិមួយៗ ត្រូវតែផ្តល់ទៅឱ្យសន្និសីទរបស់រដ្ឋភាគីនេះ នូវពត៌មានស្តីពីកម្មវិធី ផែនការ និង ការអនុវត្តន៍ទាំងឡាយរបស់ខ្លួន ក៏ដូចជាវិធានការច្បាប់ និងវិធានការផ្នែករដ្ឋបាលទាំងឡាយ នៅក្នុងការអនុវត្តន៍អនុសញ្ញានេះ ដូចដែលតំរូវឱ្យមានដោយសន្និសីទរបស់រដ្ឋភាគីនេះ ។

## មាត្រា ៣៣

### លេខាធិការដ្ឋាន:

១- អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវតែផ្តល់ទៅឱ្យសន្និសីទរបស់រដ្ឋភាគីនេះ នូវសេវាកម្មចាំបាច់នានាផ្នែកលេខាធិការដ្ឋាន សំរាប់សន្និសីទរបស់រដ្ឋភាគីទាំងឡាយនៃអនុសញ្ញានេះ ។

២- លេខាធិការដ្ឋាននេះ :

(ក) ជួយសន្និសីទរបស់រដ្ឋភាគីនេះ នៅក្នុងការសំរេចសកម្មភាពទាំងឡាយ ដែលបានចែងនៅក្នុងមាត្រា ៣២ នៃអនុសញ្ញានេះ និងរៀបចំការចាត់ចែងនានា និងផ្តល់សេវាកម្មចាំបាច់នានាសំរាប់សម័យប្រជុំរបស់សន្និសីទរបស់រដ្ឋភាគីនេះ ។

(ខ) ជួយរដ្ឋភាគីទាំងឡាយ តាមសំណើរ នៅក្នុងការផ្តល់ពត៌មានទៅឱ្យសន្និសីទរបស់រដ្ឋភាគីនេះ ដូចបានគ្រោងទុកនៅក្នុងមាត្រា ៣២ កថាខណ្ឌទី ៥ នៃអនុសញ្ញានេះ និង

(គ) ធានាឱ្យមានការសំរបសំរួលជាចាំបាច់ ជាមួយនឹងលេខាធិការដ្ឋានទាំងឡាយនៃអង្គការអន្តរជាតិ និងអង្គការក្នុងតំបន់ដែលពាក់ព័ន្ធ ។

## មាត្រា ៣៤

### ការអនុវត្តន៍អនុសញ្ញានេះ:

១- រដ្ឋភាគីនិមួយៗ ត្រូវតែចាត់វិធានការចាំបាច់នានា ដោយរាប់ទាំងវិធានការច្បាប់ និងវិធានការផ្នែករដ្ឋបាល ដែលស្របតាមគោលការណ៍ជាមូលដ្ឋាននៃច្បាប់ក្នុងស្រុករបស់ខ្លួន ដើម្បីធានាឱ្យមានការអនុវត្តន៍កាតព្វកិច្ចទាំងឡាយរបស់ខ្លួន នៅក្រោមអនុសញ្ញានេះ ។

២- បទល្មើសទាំងឡាយ ដែលបានបង្កើតឡើងស្របតាមមាត្រា ៥ មាត្រា ៦ មាត្រា ៨ និងមាត្រា ២៣ នៃអនុសញ្ញានេះ ត្រូវមានចែងនៅក្នុងច្បាប់ក្នុងស្រុករបស់រដ្ឋភាគីនិមួយៗ ដោយមិនគិតអំពីចរិកលក្ខណៈនៃការឆ្លងដែន ឬការចូលរួមពាក់ព័ន្ធរបស់ក្រុមបណ្តាញឧក្រិដ្ឋជន ដូចបានរៀបរាប់នៅក្នុង

មាត្រា ៣ កថាខណ្ឌទី ១ នៃអនុសញ្ញានេះ លើកលែងតែថាមាត្រា ៥ នៃអនុសញ្ញានេះ ដែលតំរូវឱ្យមានការចូលរួមពាក់ព័ន្ធរបស់ក្រុមបណ្ដាញឧក្រិដ្ឋជន តែប៉ុណ្ណោះ ។

៣- រដ្ឋភាគីនិមួយៗ អាចអនុម័តវិធានការទាំងឡាយ ដែលមានលក្ខណៈតឹងរឹង ឬធ្ងន់ធ្ងរជាងវិធានការទាំងឡាយ ដែលបានចែងដោយអនុសញ្ញានេះ សំរាប់ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងបណ្ដាញអំពើឧក្រិដ្ឋកម្មឆ្លងដែន ។

## មាត្រា ៣៥

## ការដោះស្រាយជំលោះទាំងឡាយ:

១- រដ្ឋភាគីទាំងឡាយ ត្រូវតែខិតខំប្រឹងប្រែងដោះស្រាយជំលោះទាំងឡាយ ដែលទាក់ទងជាមួយនឹងការបកស្រាយ ឬការអនុវត្តន៍អនុសញ្ញានេះ តាមរយៈការចរចាគ្នា ។

២- ជំលោះណាមួយរវាងរដ្ឋភាគីពីរ ឬរដ្ឋភាគីច្រើន ដែលទាក់ទងជាមួយនឹងការបកស្រាយ ឬការអនុវត្តន៍អនុសញ្ញានេះ ដែលមិនអាចដោះស្រាយបានតាមរយៈការចរចាគ្នានៅក្នុងរយៈពេលសមស្របមួយទេនោះ ត្រូវតែដាក់ជូនសំរាប់ការកាត់ក្ដីដោយអាជ្ញាកណ្ដាល តាមការស្នើសុំរបស់រដ្ឋភាគីមួយក្នុងចំណោមរដ្ឋភាគីទាំងនោះ ។ ប្រសិនបើបន្ទាប់ពីរយៈពេល ៦ ខែ នៃកាលបរិច្ឆេទនៃការស្នើសុំឱ្យមានការកាត់ក្ដីដោយអាជ្ញាកណ្ដាល រដ្ឋភាគីទាំងនោះ នៅតែមិនអាចព្រមព្រៀងគ្នាលើការរៀបចំការកាត់ក្ដីដោយអាជ្ញាកណ្ដាលនេះទេនោះ រដ្ឋភាគីណាមួយក្នុងចំណោមរដ្ឋភាគីទាំងនោះ អាចបញ្ជូនជំលោះនោះទៅកាន់តុលាការយុត្តិធម៌អន្តរជាតិ ដោយធ្វើបណ្ដឹងមួយ អោយស្របតាមលក្ខន្តិកៈរបស់តុលាការនោះ ។

៣- រដ្ឋភាគីនិមួយៗ អាចប្រកាស នៅពេលចុះហត្ថលេខា ផ្ដល់សច្ចាប័ន ការទទួលយក ឬការយល់ព្រម ឬអនុម័តទទួលយក ឬការចូលជាសមាជិកនៅក្នុងអនុសញ្ញានេះជាផ្លូវការ ថាខ្លួនមិនបានចាត់ទុកថាខ្លួនបានជាប់ចំណង ដោយកថាខណ្ឌទី ២ នៃមាត្រានេះទេ។ រដ្ឋភាគីផ្សេងៗទៀតមិនត្រូវជាប់ចំណងដោយកថាខណ្ឌទី ២ នៃមាត្រានេះទេ ចំពោះរដ្ឋភាគីណាមួយដែលធ្វើការបំរុងបែបនេះដែរ ។

៤- រដ្ឋភាគីណាមួយ ដែលបានធ្វើការបំរុង ស្របតាមកថាខណ្ឌទី ៣ នៃមាត្រានេះ អាចដកការបំរុងនោះវិញ នៅពេលណាមួយក៏បាន ដោយជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជា ជាតិ ។

## មាត្រា ៣៦

### ការចុះហត្ថលេខា ការផ្តល់សច្ចាប័ន ការព្រមទទួលយក ការអនុម័តយល់ព្រម និង ការចូលជាសមាជិក :

១- អនុសញ្ញានេះ បើកចំហចំពោះរដ្ឋទាំងអស់ ដើម្បីចុះហត្ថលេខា ចាប់ពីថ្ងៃទី ១២ ដល់ថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០០០ នៅក្នុងទីក្រុងបាឡឺម៉ូ *(Palermo)* ប្រទេសអ៊ីតាលី និងក្រោយមកទៀតនៅទីចាត់ការធំរបស់អង្គការសហប្រជាជាតិក្នុងទីក្រុងញូយ៉ក រហូតដល់ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០០២ ។

២- អនុសញ្ញានេះ បើកចំហផងដែរចំពោះបណ្តាអង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់នានា ដើម្បីចុះហត្ថលេខា ប្រសិនបើមានរដ្ឋជាសមាជិកយ៉ាងតិចណាស់ចំនួន ១ នៃអង្គការបែបនេះ បានចុះហត្ថលេខា លើអនុសញ្ញានេះស្របតាមកថាខណ្ឌទី ១ នៃមាត្រានេះ ។

៣- អនុសញ្ញានេះ គឺជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ការទទួលយក ឬការអនុម័តយល់ព្រម ឬការទទួលយកជាផ្លូវការ ។ មធ្យោបាយនៃការផ្តល់សច្ចាប័ន ការព្រមទទួលយក ឬការអនុម័តយល់ព្រមទាំងឡាយ ត្រូវតែបានដាក់ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់មួយ អាចដាក់ជូនមធ្យោបាយនៃការផ្តល់សច្ចាប័ន ការព្រមទទួលយក ឬការអនុម័តយល់ព្រមរបស់ខ្លួន ប្រសិនបើមានរដ្ឋជាសមាជិក យ៉ាងហោចណាស់ចំនួន ១ បានធ្វើដូច្នេះដែរនោះ ។ នៅក្នុងមធ្យោបាយនៃការផ្តល់សច្ចាប័ន ការព្រមទទួលយក ឬការអនុម័តយល់ព្រមនោះ អង្គការបែបនេះ ត្រូវតែប្រកាសអំពីវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួន ចំពោះបញ្ហាទាំងឡាយ ដែលបានគ្រប់គ្រងដោយអនុសញ្ញានេះ ។ អង្គការបែបនេះ ត្រូវតែជំរាបពត៌មានផងដែរដល់អ្នកទទួលអំពីការដាក់ជូននូវការកែប្រែ ដែលពាក់ព័ន្ធណាមួយនៅក្នុងវិសាលភាព នៃសមត្ថកិច្ចរបស់ខ្លួននោះ ។

៤- អនុសញ្ញានេះ គឺបើកចំហចំពោះរដ្ឋណាមួយ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ណាមួយ ដែលមានរដ្ឋជាសមាជិកយ៉ាងហោចចំនួន ១ គឺជាភាគីមួយរបស់អនុសញ្ញានេះ ដើម្បីចូលជាសមាជិក។ មធ្យោបាយនៃការចូលជាសមាជិក ត្រូវតែបានដាក់ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ នៅពេលចូលជាសមាជិកអង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់មួយ ត្រូវតែប្រកាស អំពីវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួនចំពោះបញ្ហាទាំងឡាយ ដែលបានគ្រប់គ្រងដោយអនុសញ្ញានេះ ។ អង្គការបែបនេះ ត្រូវតែជំរាបពត៌មានផងដែរដល់អ្នកទទួលអំពីការដាក់ជូននូវការកែប្រែ ដែលពាក់ព័ន្ធណាមួយនៅក្នុងវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួននោះ ។

## មាត្រា ៣៧

**ទំនាក់ទំនងជាមួយនឹងវិធីសារៈ**

១- អនុសញ្ញានេះ អាចត្រូវបានបន្ថែមដោយវិធីសារមួយ ឬវិធីសារច្រើនទៀត ។

២- ដើម្បីក្លាយខ្លួនទៅជាភាគីមួយរបស់វិធីសារមួយនោះ រដ្ឋមួយ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់មួយ ត្រូវតែជាភាគីមួយដែររបស់អនុសញ្ញានេះ ។

៣- រដ្ឋភាគីមួយរបស់អនុសញ្ញានេះ គឺមិនជាប់ចំណង ដោយវិធីសារមួយនោះទេ ដរាបណាខ្លួនបានក្លាយទៅជាភាគីមួយរបស់វិធីសារ ស្របតាមបទបញ្ញត្តិទាំងឡាយនោះ ។

៤- វិធីសារណាមួយរបស់អនុសញ្ញានេះ ត្រូវតែបានបកស្រាយរួមជាមួយនឹងអនុសញ្ញានេះផងដែរ ដោយមានការពិចារណាទៅលើកម្មវត្ថុនៃវិធីសារនោះ ។

## មាត្រា ៣៨

**ការចូលជាធរមានៈ**

១- អនុសញ្ញានេះ ត្រូវតែចូលជាធរមាននៅថ្ងៃទី ៩០ បន្ទាប់ពីកាលបរិច្ឆេទនៃការដាក់ជូនមធ្យោបាយទី ៤០ នៃការផ្តល់សច្ចាប័ន ការព្រមទទួលយក ការអនុម័តយល់ព្រម ឬការចូលជាសមាជិក។ សំរាប់គោលបំណងរបស់កថាខណ្ឌនេះ គឺថាមធ្យោបាយណាមួយ ដែលត្រូវបានដាក់ជូនដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់មួយ ត្រូវចាត់ទុកថាជាការបន្ថែមទៅលើមធ្យោបាយ ដែលត្រូវបានដាក់ជូនដោយរដ្ឋជាសមាជិកទាំងឡាយរបស់អង្គការបែបនេះ។

២- ចំពោះរដ្ឋនិមួយៗ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់និមួយៗ ដែលបានផ្តល់សច្ចាប័ន បានព្រមទទួលយក បានអនុម័តយល់ព្រម ឬចូលជាសមាជិកនៅក្នុងអនុសញ្ញានេះ បន្ទាប់ពីបានដាក់ជូននូវមធ្យោបាយសមស្របទី ៤០ អនុសញ្ញានេះ ត្រូវតែចូលជាធរមាននៅថ្ងៃទី ៣០ បន្ទាប់ពីកាលបរិច្ឆេទនៃការដាក់ជូននូវមធ្យោបាយសមស្រប ដោយរដ្ឋ ឬអង្គការនេះ ។

## មាត្រា ៣៩

**វិសោធនកម្មៈ**

១- បន្ទាប់ពីការផុតកំណត់រយៈពេលចំនួន ៥ ឆ្នាំ ចាប់ពីការចូលជាធរមាននៃអនុសញ្ញានេះទៅ រដ្ឋភាគីមួយអាចស្នើសុំការធ្វើវិសោធនកម្ម និងដាក់ជូនអត្ថបទនេះទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ

ដែលបន្ទាប់ពីនោះមក អគ្គលេខាធិការនេះត្រូវតែធ្វើទំនាក់ទំនងជាមួយនឹងបណ្តារដ្ឋភាគីទាំងឡាយ និងជាមួយនឹងសន្និសីទរបស់រដ្ឋភាគីទាំងឡាយនៃអនុសញ្ញានេះ ដើម្បីពិនិត្យសំណើរធ្វើវិសោធនកម្ម និងការសំរេចលើសំណើរនោះ ។ សន្និសីទរបស់រដ្ឋភាគីនេះ ត្រូវតែខិតខំប្រឹងប្រែងយ៉ាង ខ្លាំងក្លា ដើម្បីសំរេចបានការព្រមព្រៀងគ្នាទៅលើវិសោធនកម្មនិមួយៗ ។ ប្រសិនបើរាល់កិច្ចខិតខំប្រឹងប្រែងដើម្បីទទួលបានការព្រមព្រៀងគ្នានោះ មិនអាចសំរេចបាន ហើយគ្មានកិច្ចព្រមព្រៀងគ្នាណាមួយទេនោះ ការធ្វើវិសោធនកម្មនោះ ត្រូវតែតំរូវឱ្យមានការអនុម័តតាមការបោះឆ្នោតមតិភាគច្រើន ចំនួន ២/៣ ដែលជាជំរើសមួយចុងក្រោយបំផុតដោយរដ្ឋភាគីទាំងឡាយ ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំរបស់សន្និសីទរបស់រដ្ឋភាគី ហើយធ្វើការបោះឆ្នោត ។

២- អង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ទាំងឡាយ មានសិទ្ធិ នៅក្នុងបញ្ហាទាំងឡាយក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន បោះឆ្នោតនៅក្រោមមាត្រានេះ ដោយមានចំនួនសម្លេងឆ្នោតដែលស្មើគ្នានឹងចំនួនរដ្ឋជាសមាជិករបស់ខ្លួន ដែលជារដ្ឋភាគីរបស់អនុសញ្ញានេះ ។ អង្គការបែបនេះ មិនត្រូវអនុវត្តន៏សិទ្ធិរបស់ខ្លួនដើម្បីបោះឆ្នោតទេ ប្រសិនបើរដ្ឋជាសមាជិករបស់ខ្លួន បានអនុវត្តន៏សិទ្ធិរបស់ពួកគេរួចហើយនោះ ហើយការបញ្ច្រាសទៅវិញក៏ដូចគ្នាដែរ ។

៣- វិសោធនកម្មមួយ ដែលត្រូវបានអនុម័តស្របតាមកថាខណ្ឌទី១ នៃមាត្រានេះ ត្រូវដាក់អោយមានការផ្តល់សច្ចាប័ន ការព្រមទទួលយក ឬការអនុម័តយល់ព្រមដោយរដ្ឋភាគីទាំងនោះ ។

៤- វិសោធនកម្មមួយ ដែលត្រូវបានអនុម័តស្របតាមកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវតែចូលជាធរមានចំពោះរដ្ឋភាគីមួយ ក្នុងរយៈពេល ៩០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការដាក់ជូនមធ្យោបាយអំពីការផ្តល់សច្ចាប័ន ការព្រមទទួលយក ឬការអនុម័តយល់ព្រមទៅលើការធ្វើវិសោធនកម្មបែបនេះ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៥- នៅពេលដែលវិសោធនកម្មមួយ ត្រូវបានចូលជាធរមាន វិសោធនកម្មនោះ មានកំលាំងចាប់បង្ខំរដ្ឋភាគីទាំងនោះ ដែលបានសំដែងនូវការយល់ព្រមរបស់ខ្លួន ដែលថាខ្លួន នឹងមានជាប់ចំណងដោយការធ្វើវិសោធន៏កម្មនោះ ។ រដ្ឋភាគីផ្សេងៗទៀត ក៏ត្រូវតែនៅជាប់ចំណងជាមួយនឹងបទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ និង វិសោធនកម្មពីពេលមុនណាមួយ ដែលពួកគេ បានផ្តល់សច្ចាប័ន បានព្រមទទួលយក ឬបានអនុម័តយល់ព្រមរួចហើយ ។

មាត្រា ៤០

ការបដិសេធ :

១- រដ្ឋភាគីមួយ អាចប្រកាសបដិសេធអនុសញ្ញានេះ ដោយមានការជូនដំណឹងជាលាយលក្ខអក្សរទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ការបដិសេធនេះ ចូលជាធរមានក្នុងរយៈពេលចំនួន ១ ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលសេចក្តី ជូនដំណឹងនេះ ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២- អង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់មួយ ឈប់ធ្វើជាភាគីមួយរបស់អនុសញ្ញានេះ នៅពេលដែលរដ្ឋភាគីជាសមាជិករបស់ខ្លួនទាំងអស់ បដិសេធអនុសញ្ញានេះ ។

៣- ការបដិសេធទៅលើអនុសញ្ញានេះ ស្របតាមកថាខណ្ឌទី ១ នៃមាត្រានេះ បណ្តាលឱ្យមានការបដិសេធពិធីសារណាមួយនោះផងដែរ ។

មាត្រា ៤១

អ្នកទទួលរក្សាទុក និងភាសា:

១- អគ្គលេខាធិការអង្គការសហប្រជាជាតិ ជាអ្នកទទួលរក្សាទុកអនុសញ្ញានេះ ។

២- អត្ថបទច្បាប់ដើមនៃអនុសញ្ញានេះ ដែលមានជាភាសាអារ៉ាប់ ភាសាចិន ភាសាអង់គ្លេស ភាសាបារាំង ភាសារុស្ស៊ី និងភាសាអេស្ប៉ាញ ដែលមានលក្ខណៈពិតប្រាកដត្រឹមត្រូវស្មើគ្នា ត្រូវតែរក្សាទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

**បានធ្វើជាសាក្សីចំពោះអនុសញ្ញានេះ** អ្នកតំណាងរដ្ឋដែលមានអំណាចសំរេចលើកិច្ចការ ដែលបានចុះហត្ថលេខាខាងក្រោមនេះ ត្រូវបានផ្តល់សិទ្ធិអំណាចយ៉ាងពេញលេញដោយរដ្ឋាភិបាលរៀងៗខ្លួន ដើម្បីឱ្យចុះហត្ថលេខាលើអនុសញ្ញានេះ ។